ខុមហ្វ្រែល COMFREL

ព្រឹត្តិបត្រ ខុមហ្វ្រែល

# អ្នកឃ្លាំមើល

NEAK KLOAMMEUL

លេខ ៣៩ ឆ្នាំទី១០ ចេញថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨

## ម្ចាស់ឆ្នោតត្រូវការអ្នកជាប់ឆ្នោតគោរពតាមគោលនយោបាយ និងការសន្យាឱ្យមានប្រសិទ្ធភាព




## មាតិកា


- *អធិប្បាយលេខនេះ :* ជាបញ្ហាប៉ុន្តែមិនមែនវិបត្តិជុំវិញការបង្កើតរដ្ឋសភា និងរាជរដ្ឋាភិបាល អាណត្តិទី៤ ..............................១
- ការសង្កេតលើដំណើរការប្តឹងតវ៉ាលើលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត..............................៦
- ការព្រួយបារម្ភអំពីការបន្តធ្លាក់ចុះសិទ្ធ អំណាច និងឯករាជ្យភាពរបស់អ្នកតំណាងរាស្ត្រ..............................៨
- ទម្រង់ ១០១៨ ជាអ្វី? ..............................៩
- ការរៀបចំបន្ទំការបោះឆ្នោត និងវិធីទប់ទល់នឹងបញ្ហានេះ..............................១០
- លទ្ធផលនៃការបោះឆ្នោត២០០៨ និងប្រព័ន្ធបោះឆ្នោតនៅកម្ពុជា..............................១២


អ្នកឃ្លាំមើល : ការផ្សព្វផ្សាយរបស់គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា

**<u>អធិប្បាយលេខនេះ</u>**

# ជាបញ្ហាប៉ុន្តែមិនមែនវិបត្តិជុំវិញការបង្កើតរដ្ឋសភា និងរាជរដ្ឋាភិបាល អាណត្តិទី៤

បន្ទាប់ពីលទ្ធផលនៃការបោះឆ្នោតផ្លូវការបានផ្សព្វផ្សាយឡើង ដែលបញ្ជាក់ពីការដែល ទទួលបាននូវអាសនៈ របស់គណបក្ស ចំនួន៩ ក្នុងចំណោមគណបក្ស១១ ដែលបានចូលរួមការប្រកួតប្រជែងនៅក្នុងការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៤ កាលពីថ្ងៃ ២៧ ខែកក្កដា ឆ្នាំ ២០០៨ កន្លងទៅនេះ មានបញ្ហាជាច្រើនបានកើតឡើង ពាក់ពន្ធ័ នឹងបញ្ហានៃការបោះឆ្នោតនេះ។ ក្នុងបញ្ហាជាច្រើនដែលបានកើតឡើងដូចជាការបដិសេធមិនទទួលយកលទ្ធផលបោះឆ្នោត ពីបណ្តាគណបក្សប្រឆាំងធំៗ ការប្តឹងផ្តល់របស់គណបក្សប្រឆាំងទៅគជប និងការប្តឹងឧទ្ធរណ៏ទៅក្រុមប្រឹក្សាធម្មនុញ្ញ លើបណ្តឹងដែលត្រូវ គជប បដិសេធមិនធ្វើសវនាការដោះស្រាយ ហើយក្រុមប្រឹក្សាធម្មនុញ្ញប្រកាសដំកល់សេចក្តីសំរេច បដិសេធរបស់ គជប ទុកជាបានការទាំងស្រុង ការព្រមានធ្វើពហិការមិនចូលរួមពិធីសម្បថចូលកាន់តំណែងរបស់ គណបក្សប្រឆាំងដែលមានអាសនៈតិចក្នុងរដ្ឋសភា ។ល។

នៅក្នុងចំណោមបញ្ហាដែលបានលើកឡើងខាងលើនេះ បញ្ហាមួយដែលមានជំហរខ្វែងគ្នាក្នុងការបកស្រាយ ច្បាប់អំពីលទ្ធភាពនៃការបង្កើតរដ្ឋសភាថ្មី ដែលមានការពាក់ព័ន្ធដល់ការព្រមានធ្វើពហិការមិនចូលរួមធ្វើសម្បថរបស់ គណបក្សប្រឆាំង និងការគំរាមដកយកអាសនៈរបស់គណបក្សប្រឆាំងទៅចែកដល់គណបក្សផ្សេងៗទៀតពីគណបក្សប្រជាជនកម្ពុជា ប្រសិនបើមិនព្រមចូលរួមក្នុងថ្ងៃធ្វើសម្បថ ។ ទោះបីយ៉ាងណាក៏គណបក្សប្រឆាំងទាំងពីរ(គណបក្ស សម រង្ស៊ី និងសិទ្ធិមនុស្ស)បានបន្ទន់ ជំហរការធ្វើពហិការមិនចូលរួមធ្វើសម្បថថ្ងៃចូលកាន់តំណែងរបស់សភាអាណត្តិ ទីបួននៅថ្ងៃដំបូងជាមួយគណបក្សប្រជាជន ប៉ុន្តែស្នើឱ្យមានការប្រជុំនៅថ្ងៃបន្ទាប់ ដែលទង្វើនេះមានការបកស្រាយថាជាការប្រមាថដល់ព្រះកិត្តិយសអង្គព្រះមហាក្សត្រ ។

នៅក្នុងអាណត្តិទី៣កន្លងទៅ បន្ទាប់ពីការបោះឆ្នោតមានវិបត្តិនៃការបង្កើតសភា និងរដ្ឋាភិបាលថ្មីដែលអូសបន្លាយពេលជិត១ឆ្នាំ រហូតដល់មានការសំរបសំរួលផ្ទៃកនយោបាយ ក្នុងការបែងចែកអំណាចរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិច ហើយឈានទៅដល់ការធ្វើវិសោធនកម្មរធម្មញ្ញបោះឆ្នោតជាកញ្ចប់ ក្នុងការផ្តល់សេចក្តីទុកចិត្តពីរដ្ឋសភាដល់សមាសភាពនៃថ្នាក់ដឹងនាំអង្គនីតិបញ្ញត្តិ និងនីតិប្រតិបត្តិ ក្នុងពេលតែមួយដោយការលើកដៃ ដែលមានមតិខ្លះលើកឡើងថា វាជាការគំរាមកំហែងដល់សមាជិក សមាជិការដ្ឋសភាក្នុងការសំរេចចិត្ត និងគោលការណ៏នៃការបោះឆ្នោតដោយសំងាត់។



*ការបោះឆ្នោតជាកញ្ចប់កន្លងមក*

គួររំលឹកថានៅពេលនោះក៏មានការធ្វើពហិការពីសមាជិក សមាជិការដ្ឋសភាពីគណបក្ស សមរង្ស៊ីចំនួន ២៤រូប ដោយដើរចេញមិនរវល់នឹងការបោះឆ្នោតនេះ។ ឥឡូវនេះបញ្ហានៃការបង្កើតរដ្ឋាភិបាលថ្មី ប្រហែលជាមិនមានបញ្ហាចោទទៀតឡើយ ដោយម្យ៉ាងរដ្ឋសភាអាណត្តិទី៣ បានធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញត្រង់មាត្រា៨២ថ្មីដែលតំរូវឱ្យមានសំលេង គាំទ្រ ២ភាគ៣ ក្នុងការផ្តល់សេចក្តីទុកចិត្តពីរដ្ឋសភាដើម្បីបង្កើតរដ្ឋាភិបាលថ្មី មកនៅត្រឹមសំលេង ៥០%បូក១ប៉ុណ្ណោះ។ បើពិនិត្យមើលលទ្ធផលនៃការបោះឆ្នោតគឺគណបក្សប្រជាជនកម្ពុជា ដែលដឹកនាំប្រទេសជិត៣ទសវត្សហើយមកនោះ ទទួលបាន ៩០អាសនៈក្នុងរដ្ឋសភា មានន័យថាលើសចំនួន៥០%បូក១ ដែលចាំបាច់ត្រូវការតែចំនួន៦៣អាសនៈគឺគ្រប់គ្រាន់ ។

ប៉ុន្តែមានការភ្ញាក់ផ្អើលថា ការរៀបចំបង្កើតរដ្ឋាភិបាលថ្មីអាណត្តិទី៤នេះ គណបក្សប្រជាជនកម្ពុជាក៏មានគំរោង រៀបចំការបោះឆ្នោតជាកញ្ចប់នេះទៀត ដើមី្បជ្រើសរើសថ្នាក់ដឹកនាំរដ្ឋសភា និងផ្តល់ការទុកចិត្តដល់សមាជិកគណៈរដ្ឋមន្ត្រីក្នុងពេលជាមួយគ្នាតែម្តង។ គំរោងដំណើរការបោះឆ្នោតជាកញ្ចប់នេះតាមពិតទៅមិនមែនជាការបោះឆ្នោតឡើយ គឺជាការឱ្យសមាជិកសភាលើកដៃ ហើយគ្មានការពិភាក្សា។ ករណីនេះបង្កឱ្យមានភាពមន្ទិលសង្ស័យពីសាមគ្គីភាព និងការសំរុះសំរួលផ្ទៃក្នុងគណបក្សប្រជាជនកម្ពុជាដោយខ្លួនឯង។ ម្យ៉ាងទៀត បើតាមស្មារតីមាត្រា៣នៃច្បាប់ធម្មនុញ្ញបន្ថែម មានន័យថាការបោះជាកញ្ចប់នេះគ្រាន់តែជាជំរើសទី២

ដែលដំណើរការបោះឆ្នោតទុកចិត្តរាជរដ្ឋាភិបាលដែលអនុវត្តតាម មាត្រា៨២និងមាត្រា១១៩នៃរដ្ឋធម្មនុញ្ញមិនទទួលជោគជ័យនោះតែប៉ុណ្ណោះ។ ម្យ៉ាងទៀតអ្នកឯកទេសខាង រដ្ឋធម្មនុញ្ញ បានលើកឡើងថា ការបោះឆ្នោតកញ្ចប់នេះត្រូវបានយកមកអនុវត្តក្នុងករណីដែលមានទិដ្ឋភាពពីរយ៉ាងកើតឡើងគឺទីមួយ ស្ថាប័នជាតិមានដំណើរការមិនប្រក្រតីដែលជាគោលបំណងនៃការបោះជាកញ្ចប់នេះ និងទីពីរករណីដែលការបោះឆ្នោតជុំទី១ (ការបោះឆ្នោតដាច់ដោយឡែកពីគ្នាតាមមាត្រា៨២ និងមាត្រា១១៩) មិនទទួលជោគជ័យ។ ហើយរូបមន្តនៃការបោះឆ្នោតជាកញ្ចប់នេះមិនមានប្រទេសណាមួយលើពិភពលោកយកមកអនុវត្តទេហើយវាផ្ទុយ និងរំលោភលើគោលការណ៍ នៃការបែងចែកអំណាច និងដំណើរការប្រជាធិបតេយ្យយ៉ាងធ្ងន់ធ្ងរណាស់។

ជាមួយគ្នានេះដែរ មានការអះអាងពីគណបក្សប្រជាជនថានឹងកាន់កាប់តំណែងប្រធាន អនុប្រធានរដ្ឋសភា និង ប្រធាន អនុប្រធានគណៈកម្មការជំនាញទាំងអស់របស់រដ្ឋសភាតែម្តង ដែលទទួលការរិះគន់ពីអ្នកប្រជាធិបតេយ្យ និងសហគមន៍អន្តរជាតិ។ ជាគោលការណ៍ស្ថាប័នរដ្ឋសភា ជាស្ថាប័នតំណាងប្រជាពលរដ្ឋដោយការបោះឆ្នោត ដូចនេះ ការជ្រើសរើស និងការរៀបចំអ្នកដឹកនាំគណៈកម្មការជំនាញត្រូវយោងតាម ឬផ្អែកលើសមាមាត្រនៃសំលេងឆ្នោត ដែល គណបក្សទទួលបាន ហើយត្រូវចែងក្នុងរដ្ឋធម្មនុញ្ញតែម្តង។ ករណីនេះប្រទេសកាណាដា ច្បាប់បានកំណត់ឈ្មោះ គណៈកម្មការច្បាស់៧តែម្តងថាគណៈកម្មការណាត្រូវដឹកនាំដោយគណបក្សកាន់អំណាច ហើយគណៈកម្មការណាត្រូវដឹក នាំដោយគណបក្សប្រឆាំង ដូចជា គណៈកម្មការគណនេយ្យសាធារណៈ សិទ្ធិទទួលព័ត៌មាន ឯកជនភាព សីលធម៌ និង កិច្ចការនារី គឺប្រធានត្រូវមកពីគណបក្សប្រឆាំងផ្លូវការ អនុប្រធានទី១មកពីគណបក្សកាន់អំណាច ហើយអនុប្រធាន ទី២មកពីគណបក្សប្រឆាំងមួយផ្សេងទៀត។ ចំពោះគណៈកម្មការអចិន្ត្រៃយ៍ចំរុះទទួលបន្ទុកបទបញ្ជា និងត្រួតពិនិត្យ ប្រធានរួមគឺត្រូវមកពីគណបក្សប្រឆាំង អនុប្រធានទី១មកពីគណបក្សកាន់អំណាច ហើយអនុប្រធានទី២មកពី គណបក្សប្រឆាំងមួយផ្សេងទៀត។ រីឯគណៈកម្មការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគឺត្រូវតែដឹកនាំដោយគណបក្សកាន់អំណាច។




ឥឡូវសាកល្បងវិភាគទៅលើលទ្ធភាពដែលមិនអាចបង្កើតស្ថាប័នរដ្ឋសភាអាណត្តិទី៤ ដោយការមិនចូលរួម ធ្វើពិធីស្បថចូលកាន់តំណែងពីសំណាក់តំណាងរាស្ត្រគណបក្សសមរង្ស៊ីចំនួន ២៦ រូបនិង គណបក្សសិទ្ធិមនុស្សចំនួន ៣រូប។ ក្នុងពេលនេះដែរ ក៏មានការព្រមានពីភាគីគណបក្សប្រជាជនកម្ពុជាថានឹងធ្វើការ បែងចែកអាសនៈរបស់គណបក្សប្រឆាំង ទាំងពីរដែលមិនចូលរួមក្នុងពិធីស្បថចូលកាន់តំណែង និងប្រកាសសុពលភាពអ្នកតំណាងរាស្ត្រនេះទៅឱ្យគណបក្សផ្សេងទៀត។ ដោយយោងទៅលើបទប្បញ្ញត្តិស្តីពីការប្រកាសបោះបង់ អាសនៈរបស់គណបក្សជាប់ឆ្នោតទទួលបានអាសនៈ ក្នុងរដ្ឋសភាដែលមានចែងក្នុងច្បាប់។ បញ្ហានេះគឺត្រូវបានបកស្រាយថា ការមិនចូលរួមក្នុងសម័យប្រជុំសភាដំបូងលើក ទីមួយ ឬលើកទីពីរ ក្នុងអំឡុងហុកសិប(៦០)ថ្ងៃបន្ទាប់ពីការបោះឆ្នោតគឺមានន័យថាបោះបង់ចោលអាសនៈក្នុងរដ្ឋសភា ហើយ ដូចនេះ **គជប** ត្រូវធ្វើការបែងចែកអាសនៈដែលត្រូវបានបោះបង់ចោលទៅឱ្យគណបក្សផ្សេងទៀតដែលចូលរួម តាមរូបមន្ត ដែលមានចែងក្នុងមាត្រា១១៨ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ គណបក្សសម រង្ស៊ី និង គណបក្ស សិទ្ធិមនុស្សអាចអះអាងថា ការមិនចូលរួមក្នុងពិធីស្បថចូលកាន់តំណែងនេះមិនមែនជាការបោះបង់ចោលអាសនៈទេ ប៉ុន្តែការធ្វើពហិការមិនចូលរួមក្នុងពិធីស្បថចូលកាន់តំណែង នោះក៏បណ្តាលឱ្យតំណាងរាស្ត្រគណបក្សទាំងពីរ មិនទទួលបានសុពលភាពនោះនឹងនាំមកនូវវិបត្តិក្នុងការបង្កើតសភា។ ប៉ុន្តែពួកគេមិនបោះបង់ចោលអាសនៈរបស់ពួកគេ ដែលប្រជាពលរដ្ឋរាប់លាននាក់បានបោះឆ្នោតឱ្យនោះឡើយ។

បើតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ (សេចក្តីសំរេចលេខ០៥៤/00៥/២00៣ កបធ.ច ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២00៨) បានបកស្រាយថា : *វាក្យខ័ណ្ឌទី១នៃមាត្រា៧៦នៃរដ្ឋធម្មនុញ្ញចែងថា រដ្ឋសភាមានសមាជិក យ៉ាងតិច១២០រូប។ ត្រង់នេះមានន័យថាយ៉ាងតិចណាស់ត្រូវមានសមាជិកជាតំណាងរាស្ត្រចំនួន១២០រូប ទើបអាចបង្កើតរដ្ឋសភាក្នុងនីតិកាលនីមួយៗបាន។ ច្បាប់បោះឆ្នោតមិនអាចកំណត់ចំនួនតំណាងរាស្ត្រតិចជាង១២០រូបបានទេ។ វាក្យខ័ណ្ឌទី១នេះជាល័ក្ខខ័ណ្ឌចាំបាច់សំរាប់ការបង្កើតរដ្ឋសភា ប៉ុន្តែមិនមែនសំរាប់ដំណើរការរបស់រដ្ឋសភាទេ។ នៅពេលបោះឆ្នោតរួចហើយ លទ្ធផលត្រូវឱ្យបានតំណាងរាស្ត្រចាប់ពី១២០រូប*

*តទៅទំព័រទី ១៤*

គណៈកម្មាធិការប្រព្រឹត្តិកម្ម | ខុមហ្វ្រែល COMFREL គណៈកម្មាធិការខុមហ្វ្រែល | NICFEC គណៈកម្មាធិការនិកហ្វិច | People's Forum on CAMBODIA JAPAN

# សេចក្តីថ្លែងការណ៍រួម
## ស្តីពី
## ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី ៤ ឆ្នាំ ២០០៨ និងអនុសាសន៍អាទិភាពសម្រាប់កំណែទម្រង់ការបោះឆ្នោត

*សណ្ឋាគារសាន់វ៉េ ភ្នំពេញ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៨*

សម្ព័ន្ធអង្គការសង្គមស៊ីវិល មានដូចជា **គណៈកម្មាធិការខុមហ្វ្រែល គណៈកម្មាធិការប្រព្រឹត្តិកម្ម គណៈកម្មាធិការនិកហ្វិច វេទិកានៃប្រជាពលរដ្ឋស្តីពីកម្ពុជា-ប្រទេសជប៉ុន** PEFOC,J (ដែលមានអង្គការ-សមាគមសរុបចំនួន ៦៤ ជាសមាជិក១) យល់ឃើញថា **បរិយាកាសសន្តិសុខ ជាទូទៅ** នៅថ្ងៃបោះឆ្នោត ថ្ងៃរាប់សន្លឹកឆ្នោត និងក្រោយពេលបោះឆ្នោត **បានប្រព្រឹត្តទៅដោយសន្តិភាព លើកលែងតែនៅមុនថ្ងៃបោះឆ្នោត** ដែល**នៅមានបរិយាកាសគំរាមកំហែង បំភិតបំភ័យចំពោះសេរីភាពក្នុងការចូលរួមខាងនយោបាយ និងការបញ្ចេញមតិ**។



*សន្និសីទសារព័ត៌មានរបស់អង្គការសង្គមស៊ីវិល*

**ការសម្លាប់ ការគំរាមកំហែង ការបំភិតបំភ័យ**ដល់បេក្ខជន សកម្មជនគណបក្សនយោបាយ អ្នកសារព័ត៌មាន និងអ្នកបោះឆ្នោត បានកើតឡើងចំនួន **៥៨** ករណី នៅស្ទើរគ្រប់ខេត្ត/ក្រុង និងជាពិសេសមានការកើនឡើងក្នុងកំឡុងពីខែមេសា ឆ្នាំ២០០៨ រហូតដល់ថ្ងៃ **ស** ដែលមានចំនួន **៥៤** ករណី២។ អ្នកប្រព្រឹត្តបទល្មើសនៃអំពើហិង្សានានាក្នុងកំឡុងពេលបោះឆ្នោត មិនត្រូវបាននាំមកប្រឈមមុខច្បាប់(និទណ្ឌភាពកើនឡើង) ទោះបីយ៉ាងណាក៏ដោយ សម្ព័ន្ធអង្គការសង្គមស៊ីវិល **ស្វាគមន៍ចំពោះឆន្ទៈរបស់រាជរដ្ឋាភិបាលក្នុងកិច្ចសហការជាមួយការិយាល័យស៊ើបអង្កេតសហព័ន្ធ**(FBI) នៃសហរដ្ឋអាមេរិក ដើម្បីអង្កេតករណីឃាតកម្មទៅលើអ្នកសារព័ត៌មានលោក *ឃឹម សម្បូរណ៍* និងកូនប្រុសរបស់គាត់។ សម្ព័ន្ធអង្គការសង្គម ស៊ីវិល បន្តអំពាវនាវឱ្យអាជ្ញាធរមានសមត្ថកិច្ច **ចាត់វិធានការស៊ើបអង្កេតរកមុខឧក្រិដ្ឋជន ដែលបានល្មើសនឹងច្បាប់បោះឆ្នោត ក៏ដូចជា ច្បាប់ព្រហ្មទណ្ឌ ដើម្បីយកមកផ្តន្ទាទោស**។

សម្ព័ន្ធអង្គការសង្គមស៊ីវិលស្នើឱ្យ**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) និងក្រុមប្រឹក្សាធម្មនុញ្ញ បន្តខិតខំដោះស្រាយទំនាស់ និងបណ្តឹងនានា របស់គណបក្សនយោបាយ ដោយយកចិត្តទុកដាក់**។ លើសពីនេះ សម្ព័ន្ធអង្គការសង្គមស៊ីវិលក៏អំពាវនាវឱ្យ**អាជ្ញាធរដែលគាំទ្រគណបក្ស និងអ្នកនយោបាយ មេត្តាកុំសងសឹក ឬបំភិតបំភ័យ ឬរើសអើង**

---

1 គណៈកម្មាធិការ ខុមហ្វ្រែល មានអង្គការ-សមាគម ១១ ជាសមាជិក គណៈកម្មាធិការប្រព្រឹត្តិកម្ម មានអង្គការ-សមាគម ២១ ជាសមាជិក គណៈកម្មាធិការ និកហ្វិច មានអង្គការ-សមាគម ៧ ជាសមាជិក វេទិកានៃប្រជាពលរដ្ឋស្តីពីកម្ពុជា-ប្រទេសជប៉ុន មាន អង្គការ-សមាគម ២៥ ជាសមាជិក។

2 យោងតាមរបាយការណ៍របស់បណ្តាញខុមហ្វ្រែល-អាដហុក គិតចាប់ពីដើមឆ្នាំ ២០០៨ រហូតមកដល់បច្ចុប្បន្ន មាន ឃាតកម្ម ១៤ ករណី គំរាមកំហែង និងបំភិតបំភ័យ ៤៤ ករណី។ ពីខែ មេសា ឆ្នាំ ២០០៨ រហូតដល់ថ្ងៃ ស ទី ២៦ ខែ កក្កដា ឆ្នាំ ២០០៨ មាន ឃាតកម្ម ១២ ករណី គំរាមកំហែង និងបំភិតបំភ័យ ៤២ ករណី។

**ដល់អ្នកភូមិក្រោយពេលដឹងលទ្ធផលបោះឆ្នោតនៅតាមការិយាល័យនីមួយៗ។**



*អ្នកបោះឆ្នោតតវ៉ាពេលបាត់ឈ្មោះពីបញ្ជីបោះឆ្នោត*

សម្ព័ន្ធអង្គការសង្គមស៊ីវិល វាយតម្លៃ**ដំណើរការរៀបចំចាត់ចែងការបោះឆ្នោតថា នៅមានភាពមិនប្រក្រតី**ជាច្រើន ជាពិសេស យើងមានការ**សោកស្តាយចំពោះអ្នកបោះឆ្នោតបានទៅការិយាល័យបោះឆ្នោតប៉ុន្តែបានជួបឧបសគ្គ ដែលនាំឱ្យបាត់សិទ្ធិអ្នកបោះឆ្នោតដ៏ច្រើនជាងការបោះឆ្នោតមុនៗ**។ ការបាត់សិទ្ធិអ្នកបោះឆ្នោតនេះ ត្រូវបានកើតឡើងដោយសារ បច្ចេកទេសនីតិវិធី និងការសង្ស័យថាជាចេតនានយោបាយផងដែរ បណ្តាលមកពី**ភាពខ្វះការទទួលខុសត្រូវរបស់ គ.ជ.ប** និងអាជ្ញាធរមូលដ្ឋានឃុំ សង្កាត់ ក្នុងការចុះឈ្មោះអ្នកបោះឆ្នោតការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោត ការសម្អាត បញ្ជីឈ្មោះអ្នកបោះឆ្នោត ការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត និងកង្វះខាតជំនួយរកឈ្មោះពីសំណាក់មន្ត្រីការិយាល័យ បោះឆ្នោត។ **ការបាត់បង់សិទ្ធិអ្នកបោះឆ្នោតនេះ ក៏អាចនាំមកនូវផលប៉ះពាល់ដល់ដំណើរការ និងលទ្ធផលបោះឆ្នោត ជាពិសេស វាជាទម្រង់នៃការរំលោភសិទ្ធិមនុស្ស** ដូចជា "សិទ្ធិបោះឆ្នោត សិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត និងសិទ្ធិចូលរួមក្នុង សកម្មភាពជីវភាពនយោបាយ"។ ទន្ទឹមនឹងគ្នានេះ ការចេញទម្រង់ ១០១៨ ដោយខុសនីតិវិធី ក៏ជាបញ្ហាសំខាន់មួយដែល នាំឱ្យមានភាពមិនប្រក្រតី និងការចោទប្រកាន់ជាច្រើន។

ពាក់ព័ន្ធនឹងការបាត់សិទ្ធិអ្នកបោះឆ្នោតនេះ លោក **ធន សារាយ** ប្រធានគណៈកម្មាធិការនាយក ខុមហ្វ្រែល និងជាប្រធានសមាគមអាដហុកមានប្រសាសន៍ថា *"គេគួររៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតថ្មី និងសម្រួលនីតិវិធីឱ្យអ្នកបោះឆ្នោត មានឯកសារអាចបោះឆ្នោត និងព័ត៌មានស្តីពីការិយាល័យបោះឆ្នោតអចិន្ត្រៃយ៍ ដើម្បីធានាការគោរពសិទ្ធិបោះឆ្នោតឱ្យបានពេញលេញ"*។



*លោក ធន សារាយ ពេលសង្កេតការណ៍ថ្ងៃបោះឆ្នោត*

**បរិយាកាស និងដំណើរការបោះឆ្នោតមិនទាន់ធានាបាននូវភាពអព្យាក្រឹត និងយុត្តិធម៌បាននៅឡើយទេ** ដោយសារ តែមានការប្រើប្រាស់ធនធានរដ្ឋ និងការចូលរួមពីសំណាក់មន្ត្រីរាជការ អាជ្ញាធរ និងកងកម្លាំងប្រដាប់អាវុធ ការប្រើប្រាស់ ប្រព័ន្ធផ្សព្វផ្សាយ**ដ៏ច្រើនលើសលប់ (ជាងការបោះឆ្នោតមុនៗ)** ដើម្បីគាំទ្រគណបក្សកាន់អំណាច (គណបក្សប្រជាជន កម្ពុជា) និងកង្វះយន្តការដ៏មានប្រសិទ្ធភាពមួយក្នុងការដោះស្រាយទំនាស់ ភាពមិនប្រក្រតី និងបណ្តឹងបោះឆ្នោត-នានា។ **បញ្ហាទាំងនេះ ក៏នាំឱ្យអ្នកពាក់ព័ន្ធនឹងការបោះឆ្នោត ជាពិសេស គណបក្សនយោបាយ មិនមានទំនុកចិត្តទៅលើស្ថាប័ន គ.ជ.ប និងអាជ្ញាធរមានសមត្ថកិច្ចនានា។**




*ការប្រើប្រាសម្បត្តិរដ្ឋសំរាប់គណបក្ស*

លោក **សុក សំអឿន** ប្រធានសំរបសំរួលគណៈកម្មាធិការប្រព្រឹត្តិកម្ម និងជានាយកប្រតិបត្តិក្រុមអ្នកច្បាប់ការពារ សិទ្ធិកម្ពុជាផ្តល់យោបល់ថា *"ការកែទម្រង់ គ.ជ.ប ពិសេសយន្តការដោះស្រាយទំនាស់ និងបណ្តឹងនានា ពិតជាមានសារៈសំខាន់ ដើម្បីឱ្យមានការទុកចិត្តឡើងវិញ និងជួយឱ្យដំណើរការបោះឆ្នោតមានយុត្តិធម៌"*។




*លោក សុក សំអឿន ថ្លែងក្នុងសន្និសីទកាសែត*

សម្ព័ន្ធអង្គការសង្គមស៊ីវិល ក៏ព្រួយបារម្ភអំពីអធិករណ៍ទៅលើលទ្ធផលបោះឆ្នោត និងការបកស្រាយច្បាប់ទាក់ទិនការផ្តល់សុពលភាពដល់អ្នកតំណាងរាស្ត្រ និងការធ្វើពហិការធ្វើសច្ចាប្រណិធាន និងចូលរួមក្នុងសម័យប្រជុំដំបូងរដ្ឋសភា ដែលអាចនាំមកការបាត់បង់អាសនៈនៃគណបក្សនយោបាយមួយចំនួន។ ក្រៅពីអធិករណ៍នេះ ក៏នៅមានបញ្ហានៃការបែងចែកអំណាច និងរចនាសម្ព័ន្ធដឹកនាំក្នុងរដ្ឋសភា ព្រោះថា កន្លងមកពុំទាន់មានក្របខណ្ឌ គោលការណ៍ច្បាស់លាស់ក្រៅតែពីការស្រុះស្រួលគ្នាខាងនយោបាយប៉ុណ្ណោះ។



*លោកស្រី ពុង ឈីវកេក*

លោកស្រីវេជ្ជ. **ពុង ឈីវកេក** ប្រធានក្រុមប្រឹក្សាភិបាលគណៈកម្មាធិការនិកហ្វិច និងជាប្រធានអង្គការលីកាដូ មានមតិថា *"ដើម្បីពង្រឹងគោលការណ៍ប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អការបង្កើតរចនាសម្ព័ន្ធដឹកនាំរបស់សភាខាងមុខនេះ គួរតែត្រូវបានរៀបចំទៅតាមគោលការណ៍ស្តីពីការពង្រឹងតុល្យភាពអំណាចរវាង គណបក្សកាន់អំណាច និងគណបក្ស ប្រឆាំង។ ហេតុដូចនេះ គ្រប់គណបក្សនយោបាយដែលមានអាសនៈនៅក្នុងរដ្ឋសភា គួរណាស់ទទួលបាននូវការជ្រើសរើស ជាថ្នាក់ដឹកនាំ និងជាសមាជិកគណៈកម្មការនានានៃរដ្ឋសភា។"*

សម្ព័ន្ធអង្គការសង្គមស៊ីវិល សូមផ្តល់ជូនអនុសាសន៍ជាអាទិភាពមួយចំនួន សម្រាប់កំណែទម្រង់ការបោះឆ្នោតនៅពេលអនាគតដូចខាងក្រោម ៖

- *ភាគីពាក់ព័ន្ធការបោះឆ្នោតទាំងអស់ ត្រូវពិភាក្សាគ្នា អំពីការធ្វើកំណែទម្រង់ការចុះឈ្មោះអ្នកបោះឆ្នោត និងបញ្ជីឈ្មោះអ្នកបោះឆ្នោត និងពិចារណាអំពីការលុបចោលក្នុងការចេញ និងការប្រើប្រាស់ទម្រង់ ១០១៨។*
- *ធ្វើកំណែទម្រង់ គ.ជ.ប និងយន្តការដោះស្រាយទំនាស់ និងបណ្តឹងបោះឆ្នោត ឱ្យមានលក្ខណៈអព្យាក្រឹត និងទទួលបាននូវទំនុកចិត្តឡើងវិញពីភាគីពាក់ព័ន្ធនឹងការបោះឆ្នោត និងអ្នកបោះឆ្នោត។*
- *គួរមានច្បាប់ស្តីពីថវិកា របស់គណបក្សនយោបាយ ដែលបញ្ជាក់ឱ្យច្បាស់ពីការផ្តល់ និង/ឬការហាមប្រើប្រាស់ថវិការបស់រដ្ឋ (ជាតិ) ក្នុងការផ្តល់ផលប្រយោជន៍ដល់គណបក្សនយោបាយ ដើម្បីបង្កើនតម្លាភាពនៃការប្រើប្រាស់ថវិកា ក្នុងការឃោសនាបោះឆ្នោត។*
- *ពង្រឹងការអនុវត្តច្បាប់ និងសហលក្ខន្តិកៈដើម្បីពង្រឹងអព្យាក្រឹតភាពរបស់ចៅក្រម អាជ្ញាធរ និងកងកម្លាំងប្រដាប់អាវុធរួមទាំងនគរបាល ដែលមិនត្រូវឱ្យចូលរួមសកម្មភាពគាំទ្រគណបក្សនយោបាយ និងការឃោសនាបោះឆ្នោត (ទោះបីក្នុងម៉ោង ឬក្រៅម៉ោងធ្វើការ) ឱ្យមានប្រសិទ្ធភាព។*
- *ពង្រឹងក្របខ័ណ្ឌច្បាប់សម្រាប់ប្រព័ន្ធផ្សព្វផ្សាយដើម្បីធានាការគោរពតាមគោលការណ៍ស្មើភាព សមធម៌ និងតុល្យភាព ព័ត៌មានដល់គណបក្សនយោបាយប្រកួតប្រជែងការបោះឆ្នោតទាំងអស់។*

## សម្រាប់ព័ត៌មានផ្សេងៗ សូមទាក់ទង៖


- លោក **ធន សារាយ** ប្រធានគណៈកម្មាធិការនាយក ខុមហ្វ្រែល និងជាប្រធានសមាគមអាដហុក ០១៦ ៨៨០ ៥០៥
- លោក **សុខ សំអឿន** ប្រធានសំរបសំរួលគណៈកម្មាធិការប្រព្រឹត្តិកម្ម និងជានាយកប្រតិបត្តិCDP ០១២ ៩០១១៩៩
- លោកស្រីវេជ្ជ. **ពុង ឈីវកេក** ប្រធានក្រុមប្រឹក្សាភិបាល និកហ្វិច និងជាប្រធានអង្គការលីកាដូ ០១២ ៨០២ ៥០៦
- លោក **គល់ បញ្ញា** នាយកប្រតិបត្តិ គណៈកម្មាធិការខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៩៤២ ០១៧
- លោក **ហង្ស ពុទ្ធា** នាយកប្រតិបត្តិ គណៈកម្មាធិការនិកហ្វិច ទូរស័ព្ទ: ០១២ ៩៥៩ ៦៦៦
- Mr. **KUMAOKA Michiya** Co-Representative of PEFOC,J ទូរស័ព្ទ: ០១២ ៧៨៧ ២៧០

# ការសង្កេតលើដំណើរការប្តឹងតវ៉ាលើ លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត

ដំណើរការដោះស្រាយបណ្តឹងតវ៉ាលើលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ទាំងក្របខ័ណ្ឌច្បាប់ និងការអនុវត្តស្ថិតនៅក្នុងក៏រិតទទួលការរិះគន់ខ្លាំងនៅឡើយ។ បញ្ហានៃច្បាប់បោះឆ្នោត ដែលផ្តល់ ពេលវេលាត្រឹមតែ ៤៨ ម៉ោងដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (**គជប**) សំរាប់ដោះស្រាយបណ្តឹងថ្នាក់ ជាតិស្តីពីលទ្ធផលនៃការបោះឆ្នោត ជាចេតនាជំរុញឱ្យ **គជប** ត្រូវតែចាត់វិធានការបន្ទាន់បង្ខំក្នុងការចេញសេចក្តី សំរេចរបស់ខ្លួន។ **គជប** ខ្វះការទទួលខុសត្រូវដែលមិនព្យាយាមធ្វើការស៊ើបអង្កេត សាកសួរយកព័ត៌មានបន្ថែម និង បើកសវនាការជាសាធារណៈ ដើម្បីដោះស្រាយពាក្យបណ្តឹងរបស់គណបក្សនយោបាយទេ។ ជាការពិត **គជប** មិនធ្លាប់ ទាល់តែសោះក្នុងការលើកឡើងនូវគំនិតផ្តួចផ្តើមស្នើឱ្យធ្វើវិសោធនកម្មច្បាប់ បោះឆ្នោតពាក់ព័ន្ធនឹងការកំណត់ពេលវេលាក្នុងការដោះស្រាយពាក្យបណ្តឹងនេះ បើទោះបីជា **គជប** ធ្លាប់បានជួបប្រទះក្នុងការអនុវត្តនោះយ៉ាងណាក៏ដោយ។ ដោយផ្តេកផ្តួលនឹងខ្លឹមសារខាងលើនេះ **គជប** បានត្រឹមតែអះអាងថា **គជប** គ្មានពេលវេលាគ្រប់គ្រាន់ ជាស្ថាប័នអនុវត្ត តាមច្បាប់គោរពច្បាប់តែប៉ុណ្ណោះ។ ក្នុងការអនុវត្ត **គជប** បានព្យាយាមចេញសេចក្តីសំរេចរបស់ខ្លួនឱ្យបានឆាប់រហ័ស បំផុតតាមដែលអាចធ្វើទៅបាន ដើម្បីបញ្ជូនសំណុំរឿងឱ្យផុតពីស្ថាប័នរបស់ខ្លួន ហើយឱ្យគណបក្សនយោបាយប្តឹងបន្ត ទៅក្រុមប្រឹក្សាធម្មនុញ្ញ ដែលជាស្ថាប័នមានសិទ្ធិធ្វើសេចក្តីសំរេចចុងក្រោយ បិទផ្លូវតវ៉ាតែម្តង។



*សាវនាការរបស់ គ.ជ.ប កន្លងមក*

ក្រុមប្រឹក្សាធម្មនុញ្ញបានចាត់ចែងនីតិវិធី ក្នុងការដោះស្រាយបណ្តឹងតវ៉ាចុងក្រោយរបស់គណបក្សនយោបាយ ដូចជាបានកោះ ហៅតំណាង/មេធាវីគណបក្សនយោបាយមកបំភ្លឺ ផ្តល់ព័ត៌មាន និងភស្តុតាងដាក់បន្ទុកបន្ថែមមុនបើកសវនាការជាសាធារណៈ ការបើក ចំហដល់គូភាគីក្នុងការដាក់បន្ទុក និងការពារសំណុំរឿងរបស់ខ្លួន និងការជជែកដេញដោលផ្សេងទៀត។ ក្រុមប្រឹក្សាធម្មនុញ្ញបានធ្វើ សេចក្តីសំរេចយ៉ាងតក់ក្រហល់ ផ្អែកជាមូលដ្ឋានទាំងស្រុងទៅលើ សេចក្តីសំរេចរបស់ **គជប**។ ការពិនិត្យអង្គច្បាប់ និងការសំរេចរបស់ គជប មិនបានមានលក្ខណៈពេញលេញទេ។

បន្ថែមលើការចោទប្រកាន់ថាមានភាពលំអៀងខាងនយោបាយការធ្វើសេចក្តីសំរេចរបស់ **គជប** និងក្រុម ប្រឹក្សាធម្មនុញ្ញមិន ទាន់ទទួលបានការគាំទ្រ និងទំនុកចិត្តពីសាធារណជន និងគណបក្សនយោបាយនៅឡើយទេ។ ការសង្កេតរបស់ **ខុមហ្វ្រែល** រកឃើញ បញ្ហាមួយចំនួនដូចខាងក្រោម ទាក់ទិននឹងក្របខ័ណ្ឌច្បាប់ស្តីពីដំណើរការដោះស្រាយ បណ្តឹងតវ៉ានិងការសំរេចរបស់ **គជប** និងក្រុម ប្រឹក្សាធម្មនុញ្ញ។

### ១-ការដាក់ពាក្យបណ្តឹង

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (**គជប**) បានប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រនៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០៨។ ក្រោយពីការប្រកាសរបស់ **គជប** នេះ នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៨ មានគណបក្សនយោបាយចំនួន៣បានដាក់ពាក្យបណ្តឹងផ្សេងពីគ្នា ដើម្បីបដិសេធលទ្ធផលបណ្តោះ អាសន្ននៃការបោះឆ្នោតនេះ គឺគណបក្សសម រង្ស៊ី គណបក្សសិទ្ធិមនុស្ស និងគណបក្សនរោត្តម រណឫទ្ធិ។

គណបក្សសម រង្ស៊ីបានដាក់ពាក្យបណ្តឹចំនួន២ច្បាប់ដោយឡែកពីគ្នា គឺ ទី១ប្តឹងបដិសេធលទ្ធផល និងស្នើឱ្យរៀបចំការបោះឆ្នោតសាជាថ្មីនៅក្នុងមណ្ឌលខេត្តស្វាយរៀង និងទី២ប្តឹងបដិសេធលទ្ធផលនៅទូទាំងប្រទេស។ មូលហេតុដែលគណបក្សសមរង្ស៊ីលើកឡើងក្នុងពាក្យបណ្តឹងគឺ :

- ការផ្លាស់ប្តូរការិយាល័យបោះឆ្នោតខុសពីទីតាំងដើម និងការរកឈ្មោះក្នុងបញ្ជីមិនឃើញ
- ការបោះឆ្នោតជំនួសដោយអ្នកដែលគ្មានសិទ្ធិបោះឆ្នោត ហើយបោះលើឈ្មោះអ្នកដទៃ
- ការចេញទម្រង់ ១០១៨ នៅថ្ងៃបោះឆ្នោត ដោយខុសនឹងបទបញ្ជា និងនីតិវិធី។

ពាក្យបណ្តឹងរបស់ គណបក្សសិទ្ធិមនុស្សបានបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅទូទាំង ប្រទេស ដោយបានលើកឡើងពីភាពមិនប្រក្រតីធ្ងន់ធ្ងរដែលកើតឡើងនោះគឺ ការបំប៉ោងបញ្ជីឈ្មោះអ្នកបោះឆ្នោត ដោយបន្ថែមឈ្មោះស្ទួនក្នុងបញ្ជីបោះឆ្នោតច្រើននាក់ក្នុងការិយាល័យបោះឆ្នោតនីមួយៗ។

រីឯគណបក្សនរោត្តម រណឫទ្ធិក៏បានដាក់ពាក្យបណ្តឹមក **គជប** ផងដែរ ដើម្បីបដិសេធលទ្ធផលបោះឆ្នោតនៅ ទូទាំងប្រទេស ដោយបានលើកឡើងពីភាពមិនប្រក្រតី ការគំរាមកំហែង និងការចេញ/ប្រើប្រាស់ទំរង់ ១០១៨ ដោយ ខុសច្បាប់។

ភស្តុតាង និងឯកសារដែលគណបក្សនយោបាយដាក់ជូន **គជប** រួមមាន : ទំរង់ ១០១៨ ក្លែងបន្លំ ស្នាមមេដៃរបស់ប្រជាពលរដ្ឋដែលមិនបានបោះឆ្នោតដោយមានគេបោះជំនួស និងរកឈ្មោះមិនឃើញ ខ្សែអាត់សំលេង អត្ថបទ សារព័ត៌មានការអង្កេតអង្គហេតុ និងការសិក្សាពីលទ្ធផលឆ្នោត ទំរង់ ១១០៤ ដែលតួលេខមិនប្រក្រតី ឬគ្មានតួលេខ។

**២-ក្របខ័ណ្ឌច្បាប់**

ដើម្បីដោះស្រាយពាក្យបណ្តឹងនេះ មានមាត្រាច្បាប់មួយចំនួនដែលគេអាចយកមកពិនិត្យរួមមានដូចខាងក្រោម ។

មាត្រា១១៤ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្របានបើកផ្លូវដល់គណបក្សនយោបាយដែល ឈរឈ្មោះបោះឆ្នោតធ្វើការប្តឹងតវ៉ាអំពីលទ្ធផលមួយផ្នែក ឬលទ្ធផលទាំងអស់នៃការបោះឆ្នោតទៅ **គជប** ឬទៅក្រុម ប្រឹក្សាធម្មនុញ្ញដោយផ្ទាល់ក៏បាន។ បើតាមស្មារតីមាត្រា១១៤នេះ គណបក្សនយោបាយត្រូវបញ្ជាក់នៅក្នុងពាក្យ បណ្តឹងអំពី :

១- ភាពមិនប្រក្រតីរបស់គណៈកម្មការ ឬសមាជិកគណៈកម្មការដែលធ្វើខុស

២- កាលបរិច្ឆេទដែលធ្វើខុស

៣- ទីកន្លែងដែលមានការប្រព្រឹត្តខុស

៤- ឈ្មោះ និងអាសយដ្ឋាន សាក្សី ឯកសារ និងភស្តុតាងដទៃទៀត ។

តាមន័យចង្អៀត គណបក្សនយោបាយអាចប្តឹងតែពីភាពមិនប្រក្រតីរបស់មន្ត្រីរៀបចំការបោះឆ្នោតតែ ប៉ុណ្ណោះ ដោយមិនអាចលើកឡើងពីការរំលោភផ្សេងទៀតបានឡើយរួមទាំងការទិញសន្លឹកឆ្នោត និងការគំរាមកំហែង ខាងនយោបាយផង។ បញ្ហានៅត្រង់ថា ពាក្យបណ្តឹងត្រូវដាក់មក **គជប** ហើយប្តឹងពីមន្ត្រីរៀបចំការបោះឆ្នោតថ្នាក់ ក្រោមដែលបំរើការងារបោះឆ្នោតតាមការចាត់ចែងណែនាំ ការបណ្តុះបណ្តាលរបស់ **គជប**។ ដូចនេះ នឹងនាំឱ្យមាន ទំនាស់ខាងផលប្រយោជន៍រវាង **គជប** និងមន្ត្រីក្រោមឋានានុក្រមរបស់ខ្លួនដែលត្រូវគេប្តឹងនោះឡើយ។

ប៉ុន្តែ បើតាមមាត្រា១១១ និង១១២ គឺគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ខេត្ត ក្រុងត្រូវធ្វើសវនាការជា សាធារណៈដើម្បីដោះស្រាយបណ្តឹងតវ៉ាពីភាពមិនប្រក្រតីធ្ងន់ធ្ងរ ហើយត្រូវបញ្ជូនកំណត់ហេតុសវនាការ និងសេចក្តី សំរេចមក **គជប** ដើម្បីត្រួតពិនិត្យ។ ចំពោះ **គជប** វិញគឺត្រូវបដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យពាក់ ព័ន្ធនឹងពាក្យបណ្តឹង ក្នុងករណីមានភាពមិនប្រក្រតីកើតធ្ងន់ធ្ងរដែលធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត។ តែច្បាប់នេះមិនបានចែងពីកើតនៃភាពមិនប្រក្រតីដែលត្រូវបានចាត់ទុកថាមានលក្ខណៈធ្ងន់ធ្ងរនោះទេ ដែលជាផលវិបាកធ្វើឱ្យ **គជប** តែងតែមិនទទួលខុសត្រូវក្នុងការដោះស្រាយ មានវិធានការស៊ើបអង្កេតបន្ថែមលើពាក្យបណ្តឹង របស់គណបក្សនយោបាយ។ ជាគោលការណ៍ ភាពមិនប្រក្រតី/បទល្មើសបោះឆ្នោតដែលមានលក្ខណៈធ្ងន់ធ្ងរនោះរួម មាន ការប្រើអំពើហិង្សាកាន់កាប់ការិយាល័យបោះឆ្នោត ការបន្លំសន្លឹកឆ្នោត ការទិញសន្លឹកឆ្នោត ការគំរាមកំហែងខាងនយោបាយ ការចេញគោលនយោបាយ និងប្រតិបត្តិការមួយចំនួនទៀត ដែលធ្វើឱ្យប៉ះពាល់ដល់ភាពសេរី និងយុត្តិធម៌នៃការបោះឆ្នោត។

ម្យ៉ាងទៀត មាត្រា១១៥ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលកំណត់ ឱ្យ **គជប** ត្រូវសំរេចលើបណ្តឹងតវ៉ាតែក្នុងរយៈពេល ៤៨ ម៉ោងតែប៉ុណ្ណោះ ក្រោយពេលទទួលពាក្យបណ្តឹង។ ការកំណត់ពេល វេលាគឺជាពេលវេលាសំរាប់ដោះស្រាយពាក្យបណ្តឹង របស់គណបក្សនយោបាយដែលពាក់ព័ន្ធនឹងលទ្ធផលនៃការបោះឆ្នោតជាតិនៅទូទាំងប្រទេសជារយៈពេលបន្ទាន់បង្ខំ ដោយមិនសមហេតុផល ក្នុងការដោះស្រាយបញ្ហាដែលមានសារៈសំខាន់ ពិសេសពាក់ព័ន្ធនឹងការជ្រើសរើសថ្នាក់ដឹកនាំជាតិ។

**៣-ដំណើរការដោះស្រាយនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប)**

នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៨ **គជប** បានចេញសេចក្តីសំរេចចំនួន៣ផ្សេងពីគ្នាធ្វើការបដិសេធពាក្យបណ្តឹង របស់

តទៅទំព័រទី ១៥

# "ការព្រួយបារម្ភអំពីការបន្តធ្លាក់ចុះសិទ្ធ អំណាច និងឯករាជ្យភាពរបស់អ្នកតំណាងរាស្ត្រ"

កន្លងមកអង្គការសង្គមស៊ីវិលធ្លាប់បានសំដែងនូវការព្រួយបារម្ភចំពោះឥទ្ធិពលនៃគណបក្សនយោបាយ ទៅលើស្ថាប័ននីតិបញ្ញត្តិ(សភា និងព្រឹទ្ធសភា) និងការថយឥទ្ធិពល សិទ្ធ អំណាច និងឯករាជ្យភាព របស់អ្នក តំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភា ដោយសារការអនុវត្តន៍មាត្រា១២០នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលចែងថា សមាជិករដ្ឋសភាបាត់បង់សមាជិកភាព នៅពេលសាមីខ្លួន បាត់បង់សមាជិក ភាពពីគណបក្សនយោបាយ ។ នៅក្នុងអាណត្តិទីបួននៃរដ្ឋសភានេះប្រសិនជាការអនុវត្តមាត្រា ១២០ នៃ ច្បាប់ នេះនៅតែបន្តដូចអាណត្តិកន្លងមក នោះចរន្តនៃការធ្លាក់ចុះសិទ្ធអំណាច និងឯករាជភាពរបស់អ្នកតំណាងរាស្ត្រ ឬក៏អាចថាស្ថាបន័នីតិបញ្ញត្តិនៅកម្ពុជានឹងបន្តធ្លាក់ចុះទៀតគួរឱ្យព្រួយបារម្ភ។

វិសោធនកម្មមាត្រា១២០ នៃច្បាប់ខាងលើនេះដែលអនុម័តដោយរដ្ឋសភាបានបន្ថែម លក្ខខណ្ឌមិន ច្បាស់លាស់មួយអំពីអ្នកតំណាងរាស្ត្រដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈឹម ណាមួយក៏ត្រូវបាត់បង់សមាជិកភាព និងមាត្រា៥នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រដែលចែងថា: "តំណាង រាស្ត្រមិនអាចឆ្លៀតប្រើអភ័យឯកសិទ្ធិសភានេះដោយរំលោភនាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់បុគ្គលដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ"។ តាមមតិអ្នកវិភាគច្បាប់មួយចំនួនបានបញ្ជាក់ថា មាត្រានេះ បានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់អភ័យឯកសិទ្ធិ ពិសេសសិទ្ធ បញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រ។ អង្គការសង្គមស៊ីវិលក៏បានសង្កេតឃើញថា សិទ្ធិអំណាចរបស់អ្នកតំណាង រាស្ត្រដែលកើតចេញពីការបោះឆ្នោតគាំទ្ររបស់ប្រជាពលរដ្ឋពុំមានន័យអ្វីឡើយ គឺវាស្ថិតក្នុងកណ្តាប់ដៃរបស់គណបក្សនយោបាយទៅវិញ។ មិនតែប៉ុណ្ណោះជារឿយៗ តែងតែមានការលើកឡើងនូវសំណួរថា តើតំណាង រាស្ត្រសព្វថ្ងៃនេះបានបំពេញទៅតាមតួនាទី និងកាតព្វកិច្ចរបស់ខ្លួនសមជាអ្នកបំរើម្ចាស់ឆ្នោតដែរឬទេ? ទន្ទឹម នឹងនោះចំលើយមួយបានលើកឡើងថា សព្វថ្ងៃនេះគាត់ជាតំណាងបក្ស គឺមិនមែនជាតំណាងរបស់រាស្ត្រដែលរាស្ត្របានខិតខំបោះឆ្នោតឱ្យឡើយ។ ការលើកឡើងរបៀបនេះវាក៏ជាការមួយគួរកត់សំគាល់ផងដែរប្រសិន បើយើងធ្វើការពិនិត្យតាមដានទៅលើសកម្មភាពរបស់ អ្នកជាប់ឆ្នោតកន្លងមកជាពិសេសយោងទៅតាម របាយការណ៍សង្កេតតាមដានសកម្មភាពអ្នកតំណាងរាស្ត្រ និងសភា ដែលបានចេញផ្សាយជាទៀងទាត់រៀងរាល់ខែកន្លងមករបស់គណកម្មាធិការខុមហ្វ្រែល ឃើញថាការអនុវត្តរបស់ឯកឧត្តម លោកជំទាវសមាជិក សមាជិការដ្ឋសភាក្នុងតួនាទីបំរើផលប្រយោជន៍ជូនម្ចាស់ឆ្នោតនៅមានតិចតួចនៅឡើយ។



*កិច្ចពិភាក្សាតុមូលក្នុងកម្មវិធីសំឡេងសង្គមស៊ីវិល*

ការអនុវត្តសកម្មភាពរបស់អ្នកជាប់ឆ្នោតទាំងអស់ត្រូវតែធ្វើទៅតាមមាគ៌ារបស់គណបក្សជាជាងតាមគោលការណ៍ ឬសំណូមពរ ឬសេចក្តីត្រូវការរបស់ប្រជារាស្ត្រ។ មិនតែប៉ុណ្ណោះ ប្រសិនជាអ្នកជាប់ឆ្នោតណាដែលបាន អនុវត្តសកម្មភាពរបស់ខ្លួនមិនបានស្របទៅតាមគោលការណ៍ គោលនយោបាយគណបក្សទេនោះៗគេនឹង ត្រូវប្រឈមទៅនឹងការបាត់បង់សមាជិកភាពរបស់ខ្លួន។ ជាក់ស្តែង នៅក្នុងនីតិកាលទីបីនៃរដ្ឋសភាកន្លងទៅ មានការលើកអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រដូចជាឯកឧត្តម **ខឹម វាសនា** អតីតអ្នកតំណាងរាស្ត្រមណ្ឌលខេត្តព្រៃវែង ការដកព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ និងឯកឧត្តម ឈឹម សៀកឡេងចេញពី តំណាងរាស្ត្រ និងការប៉ុនប៉ង ដកសមាជិកភាពពីព្រឹទ្ធសមាជិកព្រះអង្គម្ចាស់នរោត្តម ចក្រពង្សពីគណបក្សហ្វ៊ុនស៊ិនប៉ិច ផងដែរ។ល។ អ្នកវិភាគមួយចំនួនក៏បានលើកឡើងដែរថា សមាជិកភាពតំណាងរាស្ត្រ គឺចេញមកពីការបោះឆ្នោត គាំទ្ររបស់ប្រជាពលរដ្ឋតាមរយៈបញ្ជីគណបក្សនយោបាយ។ ដូច្នេះការដកសមាជិកភាពតំណាងរាស្ត្រណាមួយដោយយោងលើ មូលហេតុនៃការប្រាសចាកសមាជិកភាពគណបក្សនយោបាយហើយអនុវត្តមាត្រា ១២០នៃ ច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គឺជាការរំលោភលើគោលការណ៍លទ្ធិ

ប្រជាធិបតេយ្យ។ ការអនុវត្តន៍ តាមមាត្រា១២០ នេះបាននាំមកនូវរឿងចំរូងចំរាស់នយោបាយជាច្រើន ដែលពេលខ្លះពន្យារពេល ឬមិនអាចអនុវត្តបាននៅពេលដែលអ្នកដឹកនាំសភា ថារង់ចាំការសំរេចពីតុលាការ ផ្ទុយទៅវិញករណីខ្លះពុំចាំបាច់រង់ចាំ ការសំរេចរបស់តុលាការទេ។

អង្គការសង្គមស៊ីវិលធ្លាប់បានសំដែងនូវក្ដីបារម្ភថា ការដកសមាជិកភាពជាអ្នកតំណាងរាស្ត្រ ជាបន្តបន្ទាប់នឹងនាំឱ្យស្ថាប័ននេះចុះខ្សោយទាំងអំណាច និងតួនាទីរបស់ខ្លួន និងធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ដំណើរការលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។ ការដកតំណាងរាស្ត្រក្នុងមណ្ឌលណាមួយដោយអនុវត្ត មាត្រា១២០នៃច្បាប់បោះឆ្នោតនេះ មិនត្រឹមតែខាតបង់សំរាប់មណ្ឌលនោះទេ គឺអាចជាការខាតបង់ប្រយោជន៍ និងរំលោភសិទ្ធិម្ចាស់ឆ្នោតទាំងមូលផងដែរ។ ហេតុនេះដើម្បីអាចឱ្យអ្នកតំណាងរាស្ត្រអាចមានលទ្ធភាពក្នុងការបំពេញតួនាទី ភារកិច្ច និងកាតព្វកិច្ចជាអ្នក តំណាងរាស្ត្រ ឬអាចថាបំរើដល់រាស្ត្រពិតប្រាកដ ដោយគ្មានសំពាធសង្កត់ពីគណបក្សនយោបាយរបស់ខ្លួននោះ អ្នកនយោបាយខ្មែរទាំងអស់គួរពិនិត្យលទ្ធភាពក្នុងការធ្វើវិសោធនកម្មលើមាត្រា១២០ នេះឡើងវិញ ដើម្បីធ្វើយ៉ាងណាកុំឱ្យអ្នកជាប់ឆ្នោតលុះនៅក្រោមអំណាចគាបសង្កត់របស់គណបក្សរបស់ខ្លួន គឺពួកគាត់ត្រូវតែស្ថិតនៅក្រោមអំណាចប្រជារាស្ត្រ និងបំរើរាស្ត្រពិតៗ។ អង្គការសង្គមស៊ីវិលនឹងបន្តការសិក្សានិងផ្ដល់អនុសាសន៍ លម្អិតដើម្បីកែលម្មមាត្រា ១២០ នេះ ក្នុងន័យលើកស្ទួយសិទ្ធិអំណាចអភ័យឯកសិទ្ធិរបស់សមាជិកសភា៕

# ទម្រង់ ១០១៨ ជាអ្វី?

ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៨ មានលើកឡើងពីសំណាក់គណបក្សនយោបាយ និងអង្គការសង្កេតការណ៍បោះឆ្នោតពីភាពមិនប្រក្រតីមួយចំនួន ដែលក្នុងនោះរួមមានទាំងការចេញទំរង់ ១០១៨ នៅថ្ងៃបោះឆ្នោត និងការប្រើប្រាស់ទំរង់នេះដោយក្លែងបន្លំអត្តសញ្ញាណសំរាប់យកទៅបោះឆ្នោតជំនួសឈ្មោះអ្នកដទៃលើបញ្ជី បោះឆ្នោត។

តាមការពិត បើតាមចំណុច ខ មាត្រា៥៤នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនោះ ទម្រង់១០១៨ ជាលិខិតបញ្ជាក់របស់មេឃុំ ចៅសង្កាត់ចេញដល់ប្រជាពលរដ្ឋដែលមិនមានឯកសារបញ្ជាក់អត្តសញ្ញាណអ្វីទាំងអស់ដើម្បីបំពេញបែបបទសំរាប់ការចុះឈ្មោះអ្នកបោះឆ្នោត។ ទំរង់នេះអាចបញ្ជាក់បានតែអត្តសញ្ញាណ អាយុ និងទីលំ នៅតែប៉ុណ្ណោះ គឺមិនអាចបញ្ជាក់ពីសញ្ជាតិបានឡើយ។ តាមស្មារតីមាត្រា៥៤នេះ ក្នុងការស្នើសុំទំរង់១០១៨នេះ សាមីខ្លួនត្រូវទៅបង្ហាញខ្លួនដោយផ្ទាល់ចំពោះមុខមេឃុំ ចៅសង្កាត់ ដោយផ្ទាល់ ជាមួយនឹងសាក្សី ឬអ្នកធានាចំនួន២រូប ទៀតដែលជាអ្នកមានសិទ្ធិបោះឆ្នោត ហើយបំពេញបែបបទ ផ្តិតមេដៃនៅចំពោះមុខមេឃុំ ចៅសង្កាត់។ នៅឃ្លាចុង ក្រោយនៃមាត្រានេះមានបញ្ជាក់ច្បាស់ថា *"ដើម្បីបំពេញបែបបទចុះឈ្មោះបោះឆ្នោត"*។



ទោះជាយ៉ាងនេះក្ដី នៅក្នុងបទបញ្ជា និងនីតិវិធីរបស់ គជប ប្រការ ៨.៧.១០.១ បានអនុញ្ញាតឱ្យប្រើប្រាស់ទំរង់ ១០១៨ ក្នុងការបោះឆ្នោតបាន។ មេឃុំ ចៅសង្កាត់អាចចេញទម្រង់ ១០១៨ នេះបានរហូតដល់ត្រឹមម៉ោង ៥ និង៣០នាទីល្ងាច ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៨ (១ថ្ងៃមុនថ្ងៃបោះឆ្នោត)។

ក្នុងការអនុវត្តការប្រើប្រាស់ទម្រង់ ១០១៨នេះ បង្កឱ្យមានបញ្ហាយ៉ាងស្មុគស្មាញ ដែលតាមការសង្កេត មើលទៅឃើញ មាន ក្នុងរូបភាព២យ៉ាងគឺ :

១-មេឃុំ ចៅសង្កាត់បានចេញទម្រង់ ១០១៨ នេះនៅថ្ងៃបោះឆ្នោត ដោយចុះកាលបរិច្ឆេទផ្សេង

២-ការប្រើប្រាស់ទម្រង់ ១០១៨ ក្លែងបន្លំសំរាប់បោះឆ្នោតជំនួសអ្នកដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត។

តាមការពិត ការផ្ដួចផ្ដើមឱ្យមានការប្រើប្រាស់ទម្រង់ ១០១៨ នេះគឺមានបំណងល្អ សំរាប់ជួយសំរួលដល់ប្រជាពលរដ្ឋដែល មានសិទ្ធិបោះឆ្នោត និង/ឬ មានឈ្មោះក្នុងបញ្ជីបោះឆ្នោត តែ មិនមានឯកសារបញ្ជាក់អត្តសញ្ញាណ

អ្វីទាំងអស់អាចប្រើប្រាស់សិទ្ធិបោះ ឆ្នោតរបស់ខ្លួនជាប្រជាពលរដ្ឋខ្មែរ ។ ប៉ុន្តែ អ្នកនយោបាយបានឆ្លៀតកេងយក ចំណេញពីប្រតិបត្តិការនេះ ដែលឈានទៅមានបញ្ហាយ៉ាងក្តៅគគុកក្នុងការបោះឆ្នោត ហើយ គជប ដែលបានតាក់តែង ទំរង់ ១០១៨ នេះ សំរាប់មេឃុំ ចៅសង្កាត់ ដោយភ្ជាប់ទៅជាមួយនូវរូប សញ្ញាសំគាល់ស្ថាប័ន (LOGO) របស់ខ្លួន ផងនោះ បានបដិសេធមិនទទួលខុសត្រូវពីការបង្កើត និងប្រើប្រាស់ទំរង់ ១០១៨ នេះ ហើយ ថែមទាំងមិនអាចគ្រប់ គ្រងពីចំនួនដែលទំរង់ ១០១៨ ដែលបានចេញដល់អ្នកបោះឆ្នោតទៀតផង ។

មានការជជែក ពិភាក្សាពីគណបក្សនយោបាយ អង្គការសង្គមស៊ីវិល និងភាគីដែលពាក់ព័ន្ធនឹងការបោះឆ្នោត ក្នុងការបញ្ឈប់ឱ្យមានការប្រើប្រាស់ទំរង់១០១៨នេះសំរាប់ការចុះឈ្មោះនិង/ឬ ការបោះឆ្នោតលើកក្រោយ ទៀត ។តែបញ្ហាដែលមិនអាចដោះស្រាយបាននោះបានកើតចេញរួចទៅហើយពីទំរង់ ១០១៨ នេះក្នុងការបោះឆ្នោត តំណាងរាស្ត្រឆ្នាំ២០០៨ កន្លងទៅនេះ ។

**ដោយ គាំង អេន**

## អត្ថបទស្រាវជ្រាវ : (តចប់)

# ការរៀបចំបន្លំការបោះឆ្នោត និងវិធីទប់ទល់នឹងបញ្ហានេះ

*ដោយលោក* ***Daniel Calingaert***
***Associate Director of the Center for Democracy and Election Management and professional lecturer at American University***
***Journal of Democracy Volume 17, Number 3, July 2006***
***The Johns Hopkins University Press***
*ប្រែសម្រួលដោយ កំសាន្ត*

នៅពេលតំណាងគណបក្សកាន់អំណាច និងអ្នកសង្កេតការណ៍ឯករាជ្យមិនត្រូវបានអនុញ្ញាតឱ្យចូល ឬមិនអាចចូលសង្កេតឱ្យបានគ្រប់គ្រាន់នូវដំណើរការរាប់ និងគណនាសន្លឹកឆ្នោតទេនោះ បញ្ជីរបាយការណ៍ផ្លូវការនៃលទ្ធផលបោះឆ្នោត ត្រូវបានក្លែងជារឿយៗ។ នៅបណ្ឌលរាប់សន្លឹកឆ្នោតនៅប្រទេសអេហ្ស៊ីប អំឡុងការបោះឆ្នោតតំណាងរាស្ត្រ២០០៥ អ្នកសង្កេតការបោះឆ្នោតមិនមានលទ្ធភាពសង្កេតការរាប់សន្លឹកឆ្នោតទាំងបួលបានឡើយ ដោយសារមានការកំណត់អនុញ្ញាត ឱ្យមានតែអ្នកសង្កេតការណ៍ ២នាក់ សម្រាប់បេក្ខជនឈរឈ្មោះបោះឆ្នោតម្នាក់ ទោះបីជាសន្លឹកឆ្នោតពីហិបឆ្នោតទាំងអស់ ត្រូវបានរាប់ដំណាលគ្នាក៏ដោយ។

នៅពេលខ្លះទៀត បន្ត្រីមកពីគណ:កម្មាធិការរៀបចំការបោះឆ្នោត អាចបដិសេធមិនប្រាប់គណបក្សប្រឆាំង និង សាធារណជនអំពីចំនួនសន្លឹកឆ្នោតដែលបានបោះពុម្ព និងចំនួនសន្លឹកឆ្នោតមិនទាន់គូស ដែលត្រូវចែកទៅតាមខេត្ត-ក្រុង នៅមុនថ្ងៃបោះឆ្នោតឡើយ។ ប្រការនេះធ្វើឱ្យមានការលំបាកដល់ការផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោតសរុប។ អ្នកសង្កេតការណ៍បោះឆ្នោតចាំបាច់ត្រូវដឹងពីចំនួនសន្លឹកឆ្នោតមិនទាន់គូស ដែលត្រូវបានចែកចាយ ដើម្បីប្រៀបធៀបវាទៅនឹងចំនួនសន្លឹក ឆ្នោតដែលបានបោះ ព្រមទាំងសន្លឹកឆ្នោតមិនបានការ សន្លឹកឆ្នោតខូច និងសន្លឹកឆ្នោតមិនបានប្រើ។

ការប្រកាសលទ្ធផលបោះឆ្នោតដែលមិនគួរជឿបាននោះ ជាធម្មតាបង្ហាញថា ការរាប់ និងគណនាសំឡេងឆ្នោត ត្រូវបានក្លែង។ នៅក្នុងការបោះឆ្នោតប្រធានាធិបតីប្រទេសនីហ្សេរីយ៉ាឆ្នាំ២០០៣ ដែលនៅថ្ងៃជាមួយគ្នានឹងការបោះឆ្នោត ជ្រើសរើសអភិបាលខេត្ត-ក្រុង មានការរកឃើញពីភាពមិនស្របគ្នានៅក្នុងតំបន់ខ្លះ រវាងចំនួនសន្លឹកឆ្នោតដែលបានបោះ សរុបឱ្យប្រធានាធិបតី និងអភិបាលខេត្ត-ក្រុង។ លើសពីនេះទៀត អត្រាអ្នកចេញទៅបោះឆ្នោតកម្រិតខ្ពស់មិនគួរឱ្យជឿ រហូតដល់លើស៩០% ត្រូវបានប្រកាសជាផ្លូវការនៅក្នុងរដ្ឋមួយ-ចំនួននៅក្នុងការបោះឆ្នោតនោះ។

## ការរកឃើញ និងការបង្ការ

ដោយសារនៅគ្រប់ដំណាក់កាលនៃដំណើរការបោះឆ្នោតងាយទទួលរងផលប៉ះពាល់ ការក្លែងបន្លំការបោះឆ្នោត មានការពិបាក

នឹងទប់ស្កាត់។ ទោះបីយ៉ាងណាក៏ដោយ ការសង្កេតការណ៍បោះឆ្នោតបានបង្ហាញពីពេលវេលាដ៏មានប្រសិទ្ធភាព ក្នុងការបង្ការ និងចងក្រងឯកសារស្តីពីកង្វះខាត ការក្លែង និងគៃបន្លំ ដែលប្រឈមនឹងធម្មានុរូបភាពរបស់អ្នកកាន់អំណាច ដែលស្វែងរកការរក្សាអំណាចតាមរយៈការបោះឆ្នោតដោយបន្លំ។ ដើម្បីកាត់បន្ថយការបន្លំ និងការច្នៃប្រឌិតផ្សេងៗ អ្នកសង្កេតការណ៍បោះឆ្នោតចាំបាច់ត្រូវជំរុញឱ្យមានតម្លាភាពនៅក្នុងដំណើរការបោះឆ្នោតទាំងមូល ដើម្បីទាមទារឱ្យមានតំណាងពីគណបក្សប្រឆាំង និងអ្នកឯករាជ្យនៅក្នុងគណៈកម្មាធិការរៀបចំការបោះឆ្នោត ដើម្បីអង្កេតគ្រប់ដំណាក់កាលនៃដំណើរការបោះឆ្នោតប្រកបដោយប្រសិទ្ធភាព ហើយដើម្បីចងក្រងឯកសារ ក៏ដូចជាបោះពុម្ពផ្សព្វផ្សាយអំពីការរំលោភណាមួយដែលកើតឡើង។

ច្បាប់ និងបទបញ្ញត្តិបោះឆ្នោត ដែលត្រូវបានជំរុញអនុវត្តបានល្អ និងសមស្រប គឺជាកត្តាសំខាន់សម្រាប់ធានា តម្លាភាពនៃដំណើរការបោះឆ្នោត។ បទដ្ឋានគតិយុត្តិទាំងនេះអាចលើកស្ទួយតម្លាភាព ដោយធានាការចូលរួមរបស់ភ្នាក់ងារ គណបក្សនយោបាយ និង-អ្នកសង្កេតការឯករាជ្យ ឱ្យអង្កេតការដំណើរការបោះឆ្នោតទាំងមូល តាមរយៈការតម្រូវឱ្យមន្ត្រី ការិយាល័យបោះឆ្នោតផ្សព្វផ្សាយជាសាធារណៈ និងផ្តល់សេចក្តីចម្លងរបាយការណ៍ផ្លូវការនូវលទ្ធផលបោះឆ្នោតដល់ តំណាងគណបក្ស និងដោយបង្ហាញគណៈកម្មាធិការរៀបចំការបោះឆ្នោតជាតិ ដើម្បីផ្តល់សេចក្តីលម្អិតស្តីពីចំនួនសន្លឹក ឆ្នោតមិនទាន់ប្រើ ដែលបានបោះពុម្ព និងចែកចាយ និងស្តីពីលទ្ធផលបោះឆ្នោតតាមការិយាល័យបោះឆ្នោតមួយៗ។

ភាពតំណាងនៅក្នុងគណៈកម្មាធិការរៀបចំការបោះឆ្នោត ផ្តល់ឱ្យគណបក្សប្រឆាំងនូវការសប្រេចចិត្តទៅលើនីតិវិធី និងការគ្រប់គ្រងការបោះឆ្នោត។ ការផ្តល់ឱ្យនេះអាចត្រូវបានប្រើដើម្បីបង្កើតនីតិវិធីសម្រាប់ទប់ស្កាត់ការក្លែងបន្លំ ដូចជា ការតម្រូវឱ្យមន្ត្រីការិយាល័យបោះឆ្នោតបិទត្រាលើហិបឆ្នោត រហូតទាល់តែការរាប់សន្លឹកឆ្នោតចាប់ផ្តើម ហើយ ឱ្យប្រើទឹកខ្មៅលុបមិនជ្រះបន្ទាប់ការបោះឆ្នោត។ ការចូលរួមរបស់គណបក្សប្រឆាំងនៅក្នុងគណៈកម្មាធិការរៀបចំការបោះឆ្នោត ក៏ជួយជំរុញការអនុវត្តច្បាប់ និងបញ្ញត្តិបោះឆ្នោត។ ប្រសិនបើគណៈកម្មាធិការរៀបចំការបោះឆ្នោតឯករាជ្យ ឬដែលមានការគាំទ្រពីសំឡេងជំទាស់ មិនជំរុញបញ្ហានេះ ការរំលោភច្បាប់ និងបញ្ញត្តិបោះឆ្នោតទំនងជាមិនទទួល ការពិន័យឡើយ។ លើសពីនេះទៀត តំណាងរបស់គណបក្សប្រឆាំងនៅក្នុងគណៈកម្មាធិការនេះមានសារសំខាន់ក្នុងការបង្ការការគៃបន្លំការបោះឆ្នោតជាទ្រង់ទ្រាយធំ។

តម្លាភាពនឹងគ្រាន់តែជួយតិចតួចដល់គណបក្សប្រឆាំងតែប៉ុណ្ណោះ ប្រសិនបើគណបក្សទាំងនោះមិនប្រើវាក្នុង ការសង្កេតគ្រប់ដំណាក់កាលនៃដំណើរការបោះឆ្នោតឱ្យមានប្រសិទ្ធភាពទេនោះ ពោលគឺចាប់ពីពេលចុះឈ្មោះបោះឆ្នោត រហូតដល់ការរាប់គណនាសន្លឹកឆ្នោត។ ការវាយតម្លៃលើបញ្ជីចុះឈ្មោះអ្នកបោះឆ្នោតគឺមានលក្ខណៈចំៗ ទោះបីជាត្រូវ ប្រើកម្លាំងពលកម្មច្រើនក៏ដោយ។ អ្នកសង្កេតការណ៍បោះឆ្នោត ក៏គួរតែធ្វើការវាយតម្លៃដាច់ដោយឡែក ដើម្បីរកមើល ថាតើបញ្ជីអ្នកបោះឆ្នោតមានលក្ខណៈពេញលេញដែរឬទេ។ ដើម្បីធ្វើដូច្នេះបាន ពួកគេធ្វើទស្សនកិច្ចប្រជាជនក្នុងស្រុក តាមគំរូជ្រើសរើសដោយចៃដន្យ កំណត់អត្តសញ្ញាណប្រជាពលរដ្ឋពេញវ័យ ហើយបន្ទាប់បកស្វែងរកឈ្មោះរបស់ពួកគេ នៅលើបញ្ជីអ្នកបោះឆ្នោត។ ប្រជាជនពេញវ័យដែលត្រូវបានគេលុបចេញពីបញ្ជីអ្នកបោះឆ្នោត ទំនងជាអ្នកមានសិទ្ធិបោះឆ្នោត ដែលត្រូវបានលុបបំបាត់សិទ្ធិបោះឆ្នោត។

នៅអំឡុងពេលយុទ្ធនាការបោះឆ្នោត អ្នកសង្កេតការណ៍ចាំបាច់ត្រូវអង្កេតមើលការប្រើប្រាស់បណ្តាញព័ត៌មានរបស់បេក្ខជន ហើយត្រូវកំណត់មើលនូវការរំលោភលើការប្រើប្រាស់ធនធានរបស់រដ្ឋសម្រាប់គោលបំណងយុទ្ធនាការបោះឆ្នោត។ ដោយការធ្វើសេចក្តីរាយការណ៍អំពីការរកឃើញរបស់ខ្លួន ខណៈពេលយុទ្ធនាការកំពុងប្រព្រឹត្តទៅ អ្នកសង្កេតការណ៍អាចទាញការចាប់អារម្មណ៍ទៅលើការប្រកួតប្រជែងមិនយុត្តិធម៌ ហើយអាចបង្កើតជាគំនាបដល់មន្ត្រីរៀបចំការបោះឆ្នោត ដើម្បីឱ្យពួកគេកែតម្រូវអតុល្យភាពនៃការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ឬការប្រើធនធានរបស់រដ្ឋដោយខុសឆ្គង។

ដើម្បីសង្កេតនៅថ្ងៃបោះឆ្នោតឱ្យមានប្រសិទ្ធភាព គណបក្សប្រឆាំងទាំងឡាយ និងបណ្តាអង្គការមិនលម្អៀង ចាំបាច់ត្រូវដាក់ពង្រាយអ្នកសង្កេតការណ៍ដែលទទួលការបណ្តុះបណ្តាល ទៅកាន់គ្រប់ការិយាល័យបោះឆ្នោត និងគ្រប់បណ្ឌុល រាប់សន្លឹកឆ្នោតនៅក្នុងប្រទេស។ អ្នកសង្កេតការទាំងនេះនឹងមានប្រសិទ្ធភាពតែប្រសិនបើពួកគេត្រូវបានបណ្តុះបណ្តាលឱ្យធ្វើការបែងចែករវាងពាក្យចចាមអារ៉ាម និងអង្គហេតុ (ដោយសារពាក្យចចាមអារ៉ាមស្តីពីការបន្លំក្នុងការបោះឆ្នោតជារឿងធម្មតា នៅក្នុងការបោះឆ្នោតប្រកបដោយការប្រកួតប្រជែងដ៏តឹងតែង) ហើយឱ្យចេះរៀបចំឯកសារ និងធ្វើរបាយការណ៍ ឱ្យបានសមស្របចេញពីការអង្កេតរបស់ខ្លួន អំពីហេតុនៃការបន្លំសន្លឹកឆ្នោត។ គណបក្សប្រឆាំង និងអ្នកសង្កេតឯករាជ្យ ក៏ចាំបាច់ត្រូវទាក់ទងជាមួយអ្នកសង្កេតការណ៍អន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយអំពីការរកឃើញ

របស់ខ្លួន ដើម្បីទាញការចាប់អារម្មណ៍របស់ពិភពលោក ដល់ការកែបន្លំសន្លឹកឆ្នោត។

ដោយការអំពាវនាវឱ្យមានការយកចិត្តទុកដាក់ដល់ប្រភេទផ្សេងៗនៃការបន្លំសន្លឹកឆ្នោតនៅថ្ងៃបោះឆ្នោត អ្នកសង្កេតការណ៍បោះឆ្នោតអាចធ្វើឱ្យសាធារណជនដឹងពីការគំរាមកំហែងដែលអាចកើតឡើងចំពោះការបោះឆ្នោតដោយយុត្តិធម៌។ ពួកគេក៏អាចជួយដល់ការកាត់បន្ថយការបន្លំ ដោយការរំលឹកមន្ត្រីរៀបចំការបោះឆ្នោត និងភ្នាក់ងាររបស់គណបក្សកាន់ អំណាចអំពីទណ្ឌកម្មផ្លូវច្បាប់ចំពោះការរំលោភលើច្បាប់បោះឆ្នោត និងដោយការជំរុញឱ្យមានសន្យាថាធ្វើឱ្យបានបង្ស៊ីតនូវ ការអនុវត្តន៍ទោសទណ្ឌទាំងនេះចំពោះរាល់អំពើរំលោភ។

នៅពេលខ្លះ ការសង្កេតការបោះឆ្នោតប្រកបដោយប្រសិទ្ធភាពអាចជាការជួសឱ្យកង្វះតម្លាភាពនៅក្នុងដំណើរការបោះឆ្នោត។ ឧទាហរណ៍ ការគណនាសន្លឹកឆ្នោតទន្ទឹមគ្នាមួយ អាចជួយដល់ការពិនិត្យមើលភាពត្រឹមត្រូវនៃលទ្ធផលបោះឆ្នោតជាផ្លូវការ។

នៅក្នុងការឆ្លើយតបទៅនឹងប្រសិទ្ធភាពរបស់អ្នកសង្កេតការណ៍ ក្នុងការបង្ហាញអំពើរំលោភនានាក្នុងការបោះឆ្នោត របបផ្តាច់ការបានចាប់ផ្តើមប្រើឧកលក្នុងការសង្កេតការណ៍នេះតែប្តង។ ពួកគេបានអញ្ជើញក្រុមដែលមានគេស្គាល់តិចតួច ជារឿយៗគឺជាក្រុមដែលផ្តល់សន្តានចិត្តចំពោះរបបនោះតែប្តង ឱ្យដាក់ពង្រាយអ្នកសង្កេតការណ៍ដែរ ហើយនឹងដាក់ចេញ ការវាយតម្លៃជាវិជ្ជមានទៅលើការបោះឆ្នោតដែលត្រូវបានកែបន្លំនោះ។ ជាឧទាហរណ៍ នៅប្រទេសអាហ្សែបៃហ្សង់ ក្រុមចំពោះកិច្ចនៃអ្នកសង្កេតការណ៍អាមេរិកមួយក្រុមបានលើកសរសើរ ការបោះឆ្នោតសភានៅឆ្នាំ ២០០៥ ទោះបីជាបេសកកម្មសង្កេតការណ៍បោះឆ្នោតអន្តរជាតិជាផ្លូវការ ដែលដឹកនាំដោយអង្គការដើម្បីសន្តិសុខ និងកិច្ចសហប្រតិបត្តិការនៅអឺរ៉ុបបានធ្វើសេចក្តីសន្និដ្ឋានថា ការបោះឆ្នោតនោះមិនលុះតាមបទដ្ឋានប្រជាធិបតេយ្យក៏ដោយ។ ក្រុមចំពោះកិច្ចនោះបានទទួលការឧបត្ថម្ភដោយគណៈកម្មាធិការកណ្តាលរៀបចំការបោះឆ្នោតនៃប្រទេសអាហ្សែបៃហ្សង់ ហើយដូច្នេះមិនគួរមានតួនាទី ណាមួយដែលអាចផ្តល់នូវការកាត់សេចក្តីឯករាជ្យគួរឱ្យជឿជាក់បានទៅលើដំណើរការបោះឆ្នោតនោះបានឡើយ។

នៅខែតុលា ឆ្នាំ២០០៥ នៅឯពិធីមួយរៀបចំដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ បណ្តាអង្គការសង្កេតការណ៍បោះឆ្នោតអន្តរជាតិដែលត្រូវបានបង្កើតឡើងហើយនោះ រួមទាំងអង្គការមិនមែនរដ្ឋាភិបាល និងអន្តររដ្ឋាភិបាលបានចុះហត្ថលេខាលើសេចក្តីប្រកាសស្តីពីគោលការណ៍សម្រាប់ការសង្កេតការណ៍បោះឆ្នោតអន្តរជាតិ។ សេចក្តីប្រកាសនេះកំណត់នូវគោលការណ៍នានា សម្រាប់ការសង្កេតការបោះឆ្នោតដោយមិនលម្អៀង ហើយដូច្នេះជួយសម្រួល ដល់ការបែងចែកឱ្យដាច់ពីគ្នារវាងបេសកកម្មសង្កេតការណ៍ ដែលមានការទទួលស្គាល់ត្រឹមត្រូវ ពីបេសកកម្មដទៃទៀតដែល ខ្វះការជឿទុកចិត្តពីសាធារណជន៕

# លទ្ធផលនៃការបោះឆ្នោត២០០៨ និង ប្រព័ន្ធបោះឆ្នោត នៅកម្ពុជា

ប្រពន្ធ័បោះឆ្នោតនៅកម្ពុជា គួរត្រូវសើរើពិនិត្យដើម្បីកែលំអក្នុងការធានាឱ្យមានសេរីពហុបក្ស ទាំងនៅក្នុងអភិក្រម និងទាំងសិទ្ធបោះឆ្នោត។ គណបក្សនយោបាយគួរដកការរៀនសូត្រពីការចូលរួមក្នុងដំណើរការបោះឆ្នោតមុនៗ។

ក្នុងការបោះឆ្នោតសភាធម្មនុញ្ញឆ្នាំ១៩៩៣ ដែលរៀបចំ និងគ្រប់គ្រងដោយអង្គការសហប្រជាជាតិនោះ បានយកប្រព័ន្ធតំណាងសមាមាត្រមកអនុវត្ត ជាមួយនឹងរូបមន្តសំណល់ច្រើនបំផុត។ នៅពេលនោះគឺគេយកសន្លឹកឆ្នោត ទាំងអស់មកធ្វើការបូកសរុប និងចែកអាសនៈនៅថ្នាក់ជាតិតែម្តង ដែលធ្វើឱ្យគណបក្សតូចៗដែលទទួលសំលេងឆ្នោតតិចអាចទទួលអាសនៈបន្ថែមខ្លះ ហើយគណបក្សម៉ូលីណាកា ក៏អាចទទួលបានអាសនៈ១ ក្នុងសភាធម្មនុញ្ញផងដែរ។

ចាប់ពីឆ្នាំ១៩៩៨ មក គ្រប់ការបោះឆ្នោតទាំងអស់ត្រូវអនុវត្តតាមប្រព័ន្ធសមាមាត្រ ជាមួយនឹងរូបមន្តមធ្យម ភាគខ្ពស់បំផុត ទាំងការបោះឆ្នោតតំណាងរាស្ត្រ ការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ រហូតដល់ការបោះឆ្នោតព្រឹទ្ធសភា ទៀតផង។ ទៅថ្ងៃអនាគតប្រព័ន្ធនេះនឹងត្រូវបានយកមកប្រើក្នុងការបោះឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌបន្តទៀត។

ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០០២ មានសម្ព័ន្ធអង្គការសង្គមស៊ីវិលបានធ្វើការ តស៊ូមតិស្នើសុំឱ្យមានការបោះឆ្នោតតាមប្រព័ន្ធឯកត្តនាម ដើម្បីជ្រើសរើសអ្នកដឹកនាំថ្នាក់មូលដ្ឋានមួយនេះ ឬយ៉ាង ហោចណាស់ក៏គួរអនុវត្តប្រព័ន្ធបោះឆ្នោតចំរុះដែលបេក្ខជនមកពីគណបក្សនយោបាយក៏អាចឈរឈ្មោះបានហើយបេក្ខជន ឯករាជ្យដែលមិនមែនគណបក្សនយោបាយ

ក៏អាចឈរឈ្មោះបាន។ ទោះបីអនុសាសន៍ទទួលត្រូវបានទទួលការ គាំទ្រយ៉ាងពេញទំហឹងពីគណបក្សមិនកាន់អំណាច និងការគាំទ្រជាគោលការណ៍ពីក្រសួងមហាផ្ទៃយ៉ាងណាក៏ដោយ ចុងក្រោយអនុសាសន៍នេះត្រូវបានបដិសេធចោលទាំស្រុង ហើយប្រព័ន្ធសមាមាត្រត្រូវបានអនុម័តជាផ្លូវការ។

ជាគោលការណ៍ប្រព័ន្ធតំណាងសមាមាត្រត្រូវបានប្រើសំរាប់មណ្ឌលបោះឆ្នោតដែលមានអាសនៈចាប់ពី២ឡើងទៅ។ តែនៅកម្ពុជា មានខេត្ត ក្រុងចំនួន ៩ ដែលមានអាសនៈតែ១ ក៏ត្រូវតែប្រើប្រព័ន្ធតំណាងសមាមាត្រនេះផងដែរ (ក្រុងកែប ក្រុងព្រះសីហនុ ខេត្តកោះកុង ក្រុងប៉ៃលិន ខេត្តឧត្តរមានជ័យ ព្រះវិហារ ស្ទឹងត្រែង រតនគីរីនិងមណ្ឌលគីរី)។ តាមការពិត ស្របតាមស្ថានភាពភូមិសាស្ត្រជាក់ស្តែង ខេត្ត ក្រុងទាំង៩នេះ គួរតែរៀបចំការបោះឆ្នោតតាមប្រព័ន្ធ ឯកត្តនាមដែលបេក្ខជនឈរឈ្មោះជាបុគ្គល ឬយ៉ាងហោចណាស់គួរប្រើប្រព័ន្ធភាគច្រើននិយមដោយបញ្ជី (Système Majoritaire de List) ហើយបើកចំហដល់ក្រុមបេក្ខជនឯករាជ្យអាចចូលរួមប្រកួតប្រជែងផងដែរ។



*ប្រជាពលរដ្ឋតម្រង់ជួរចូលបោះឆ្នោត*

ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ កន្លងទៅនេះ ច្បាប់បោះឆ្នោតបាន កំណត់យកប្រព័ន្ធ សមាមាត្រ និងការបែងចែកអាសនៈនៅសល់តាមរូបមន្តមធ្យមភាគខ្ពស់បំផុត។ គណនាតាមរូបមន្តនេះ លទ្ធផលជាផ្លូវការដែល ប្រកាសដោយ គជប គឺគណបក្សប្រជាជនកម្ពុជាទទួលបាន ៣ ៤៩២ ៣៧៤ សន្លឹក ស្មើនឹង ៩០ អាសនៈ (ជាមធ្យមគឺ ៣៨ ៨០៤ សន្លឹក ក្នុង១អាសនៈ) គណបក្សសម រង្ស៊ីទទួលបាន ១ ៣១៦ ៧១៤ សន្លឹក ស្មើនឹង ២៦ អាសនៈ (ជាមធ្យមគឺ ៥០ ៦៤២ សន្លឹក ក្នុង១អាសនៈ) គណបក្សសិទ្ធិមនុស្សទទួលបាន ៣៩៧ ៨១៦ សន្លឹក ស្មើនឹង ៣ អាសនៈ (ជាមធ្យមគឺ ១៣២ ៦០៥ សន្លឹក ក្នុង១អាសនៈ) គណបក្សនរោត្តម រណឬទ្ធិ ទទួលបាន ៣៣៧ ៩៤៣ សន្លឹក ស្មើនឹង ២ អាសនៈ (ជាមធ្យមគឺ ១៦៨ ៩៧១ ក្នុង១អាសនៈ) គណបក្សហ្វ៊ុន ស៊ិន ប៉ិច ទទួលបាន ៣០៣ ៧៦៤ សន្លឹក ស្មើនឹង ២ អាសនៈ (ជាមធ្យមគឺ ១៥១ ៨៨២ ក្នុង១អាសនៈ)។

តាមការសិក្សាពីតួលេខខាងលើ បង្ហាញថា ប្រព័ន្ធនេះគឺជួយគណបក្សធំឱ្យចំណេញពីការបែងចែកអាសនៈ នៅសល់យ៉ាងច្រើនលើសលប់ អាចនិយាយបានថាគណបក្សធំទទួលបានអាសនៈច្រើនជាងសមាមាត្រសន្លឹកឆ្នោតដែល ខ្លួនបានទទួលទៅទៀត។ ក្នុងលទ្ធផលខាងលើយើងឃើញថា ក្នុងទូទាំងប្រទេស គណបក្សប្រជនកម្ពុជាត្រូវការសំលេងឆ្នោតគិតជាមធ្យមតែជាង៣ម៉ឺនសន្លឹកប៉ុណ្ណោះដើម្បីទទួលបាន១អាសនៈ រីឯគណបក្សសម រង្ស៊ីត្រូវការចំនួនជាង ៥ម៉ឺនសន្លឹក ហើយរហូតដល់ជាង១០ម៉ឺនសន្លឹកសំរាប់គណបក្សសិទ្ធិមនុស្ស គណបក្សហ្វ៊ុនស៊ិនប៉ិច និងគណបក្ស នរោត្តមរណឬទ្ធិ។

ម្យ៉ាងទៀត បើមើលពីភាគរយនៃសន្លឹកឆ្នោត ដែលគណបក្សនយោបាយទទួលបានវិញ :

- គណបក្សប្រជាជនកម្ពុជាទទួលបានសំលេងឆ្នោតចំនួន ៥៨,១១% ទទួលអាសនៈបានរហូតដល់ ៧៣,១១%
- គណបក្សសម រង្ស៊ីទទួលបានសំលេងឆ្នោតចំនួន ២១,៩១% ទទួលអាសនៈបាន ២១,១៤%
- គណបក្សសិទ្ធិមនុស្សទទួលបានសំលេងឆ្នោតចំនួន ៦,៦២% ទទួលអាសនៈបានតែ ២,៤៤%
- គណបក្សនរោត្តម រណឬទ្ធិទទួលបានសំលេងឆ្នោតចំនួន ៥,៦២% ទទួលអាសនៈបានតែ ១,៦៣%
- គណបក្សប្រជាជនកម្ពុជាទទួលបានសំលេងឆ្នោតចំនួន ៥,០៥% ទទួលអាសនៈបានតែ ១,៦៣%។

តាមកាសិក្សាខាងលើឃើញថាមានតែគណបក្សសម រង្ស៊ីទេ ដែលទទួលបានអាសនៈសមាមាត្រនឹងសំលេងឆ្នោត រីឯគណបក្សប្រជាជនកម្ពុជាទទួលបានអាសនៈច្រើនជាងសមាមាត្រសន្លឹកឆ្នោតដែលបានទទួល ហើយយើង ឃើញភាពលំអៀងខ្លាំងធ្លាក់លើគណបក្សសិទ្ធិមនុស្ស នរោត្តម រណឬទ្ធិ និងហ្វ៊ុនស៊ិនប៉ិច ដែលខាតបង់ ដោយចោល សន្លឹកឆ្នោតនៅតាមមណ្ឌលខេត្តក្រុងច្រើនលើសលប់។

ជាមួយគ្នានេះដែរបើយើងសាកល្បងយកលទ្ធផលដែលប្រកាសដោយ គជប នៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០៨ មកគណនាប្រព័ន្ធអ៊ិនពាក់ដែលអនុវត្តនៅឆ្នាំ១៩៩៣គឺប្រព័ន្ធសមាមាត្រ រូបមន្តសំណល់ច្រើនបំផុតហើយសរុបលទ្ធផល និងគណនាអាសនៈទូទាំងប្រទេសនោះគឺ :

*តទៅទំព័រទី ១៧*

*តមកពីទំព័រទី២*

## ជាបញ្ហាប៉ុន្តែមិនមែនវិបត្តជុំវិញការបង្កើតរដ្ឋសភា និងរាជ...

*ឡើងទៅ ទៅតាមការកំណត់នៃច្បាប់ បោះឆ្នោតទើបអាចបង្កើតរដ្ឋសភានីតិកាលថ្មី មួយបានដោយគោរពទៅតាមនីតិវិធីដែលមាន-ចែងក្នុងមាត្រា៨២ នៃរដ្ឋធម្មនុញ្ញ និងប្រការ៣នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា ។ គឺថារដ្ឋសភាដែលកើតចេញពីការបោះឆ្នោតត្រូវចូលកាន់តំណែងជាផ្លូវការនៅពេលសម័យប្រជុំដំបូងតាមកាកោះប្រជុំរបស់ព្រះមហាក្សត្រ ហើយនឹងមានការប្រកាសសំរេចសុពលភាពអ្នកតំណាងរាស្ត្របិទផ្សាយក្នុងមន្ទីររដ្ឋសភា និងជាសាធារណៈ។ ការវិភាគខាងលើនេះបង្ហាញ ឱ្យឃើញថា ការប្រែប្រួលនៃចំនួនតំណាងរាស្ត្រក្នុងរយៈវេលានៃការប្រព្រឹត្តទៅនៃនីតិកាលមិនអាចធ្វើឱ្យប៉ះពាល់ដល់សុពលភាពរដ្ឋសភាទាំងមូលបានឡើយ ។ ដូច្នេះទោះបីចំនួនតំណាង រាស្ត្រប្រែប្រួលចុះថយក្រោម១២០រូប យ៉ាងណាក៏ដោយកុំឱ្យ តែទាបជាកូរ៉ុមប្រាំពីរភាគដប់នៃសមាជិករដ្ឋសភាទាំងមូល ក៏រដ្ឋសភានៅតែអាចដំណើរការបានដូចធម្មតា ហើយជា ពិសេសការប្រជុំពេញអង្គជាសាមញ្ញ ឬវិសាមញ្ញក៏អាច ប្រព្រឹត្តទៅបាន រហូតដល់រដ្ឋសភាថ្មីចូលកាន់តំណែងដោយពុំ មានអ្វីខុសនឹងរដ្ឋធម្មនុញ្ញឡើយ ។*

អ្នកឯកទេសខាងរដ្ឋធម្មនុញ្ញខ្លះបានបញ្ជាក់ថា ការមិនមានការចាប់ផ្តើមដោយមានតំណាងរាស្ត្រ១២០រូបនេះ គឺថាអាចនឹងធ្វើឱ្យមានការរាំងស្ទះដល់ការរៀបចំរដ្ឋសភាថ្មី ហើយថាមិនមានការបង្កើតបាននូវរដ្ឋសភាថ្មីនេះ វាក៏នឹង មិនអាចបង្កើតរដ្ឋាភិបាលថ្មីនោះដែរ។ ម្យ៉ាងទៀត តាមស្មារតីមាត្រា៨២នៃរដ្ឋធម្មនុញ្ញការបើកសម័យប្រជុំរដ្ឋសភា ដំបូងនេះគឺប្រារព្ធធ្វើឡើងតាមការកោះអញ្ជើញរបស់ព្រះមហាក្សត្រ ដូចនេះការកំណត់កាលបរិច្ឆេទនៃការប្រជុំរដ្ឋសភា ដំបូងនេះគឺជាព្រះរាជសិទ្ធិផ្តួចផ្តើមរបស់ព្រះអង្គផ្ទាល់ មិនមែនគណបក្សនយោបាយណាមួយមានសិទ្ធិកំណត់ថ្ងៃប្រជុំនេះទេ។ ប៉ុន្តែយ៉ាងណាក៏ដោយ វិបត្តនៃការបង្កើតសភាមិនមានទៀតទេ ព្រោះថាគណបក្សប្រឆាំងសម សង្ស៊ី និង សិទ្ធិមនុស្សបានបន្ទន់ជំហរថាគណបក្សខ្លួននឹងចូលប្រជុំសភាដំបូងនៅថ្ងៃ២៥ កញ្ញា ដោយបន្តពហិការការចូលរួមប្រជុំ ដំបូងជាមួយគណបក្សប្រជាជនកម្ពុជានៅថ្ងៃទី២៤កញ្ញា។

ម្យ៉ាងទៀត យោងតាមលិខិតលេខ : ២០/២០០៣ កបធ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៣ របស់ក្រុមប្រឹក្សា ធម្មនុញ្ញក្រាបបង្គំទូលថ្វាយព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ (នៅពេលនោះព្រះអង្គជាព្រះមហាក្សត្រនៃ ព្រះជាណាចក្រកម្ពុជា) បានទូលថ្វាយព្រះអង្គថា "*...មាត្រា៨២នៃរដ្ឋធម្មនុញ្ញដែលជាផ្នែកមួយនៃនីតិវិធីនេះពុំមានចែង តំរូវឱ្យមានចំនួនតំណាងរាស្ត្រ១២០រូបយ៉ាងតិចទេ ក្នុងពេលបើកសម័យប្រជុំដំបូង ហើយប្រការ៥នៃបទបញ្ជាផ្ទៃក្នុង រដ្ឋសភាក៏ឥតមានចែងដែរ ...*"។

ក្នុងន័យខាងលើនេះមានន័យថា ក្នុងសម័យប្រជុំដំបូងរបស់រដ្ឋសភាដែលត្រូវប្រកាសសុពលភាពអ្នកតំណាងរាស្ត្រ និងធ្វើសច្ចាប្រណិធានចូលកាន់តំណែងមិនតំរូវឱ្យមានតំណាងរាស្ត្រចំនួន១២០រូបយ៉ាងតិចចូលរួមទេ ហើយការប្រជុំផ្តល់សុពលភាពអ្នកតំណាងរាស្ត្រសំរាប់គណបក្សផ្សេងទៀតអាចធ្វើបន្តបន្ទាប់។

ការប្រជុំដាច់ពីគ្នានេះជាសញ្ញាទំនាស់ជ្រាលជ្រៅរវាងគណបក្សកាន់អំណាច និងគណបក្សប្រឆាំងដែលពិបាក នឹងរកការសំរុះសំរួលសមស្របណាមួយ។ នៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០០៨ ព្រះមហាក្សត្រ ចេញព្រះរាជលិខិតកោះ អញ្ជើញបេក្ខជនជាប់ឆ្នោតទាំង១២៣រូប ឱ្យចូលរួមប្រជុំរដ្ឋសភានីតិកាលទី៤នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០០៨ វេលា ម៉ោង៨.៣០នាទីព្រឹកនៅវិមានរដ្ឋសភា។ ក្រោយការកោះប្រជុំរបស់ព្រះមហាក្សត្រនេះ គណបក្សសិទ្ធិមនុស្សប្រកាស ថានឹងចូលរួមតាមការកោះអញ្ជើញ ដោយគោរពព្រះមហាក្សត្រ ព្រោះគោលការណ៍របស់ គណបក្សសិទ្ធិមនុស្ស គឺដង្ហែ តាមព្រះរាជតំរិះរបស់ព្រះមហាក្សត្រ។ ចំណែកឯគណបក្សសម រង្ស៊ីនៅតែប្រកាសរក្សាជំហរចាស់របស់ខ្លួនគឺមិនចូល រួមសម័យប្រជុំសភាដំបូងជាមួយគណបក្សប្រជាជនកម្ពុជាទេ ហើយគណបក្សបានដាក់លិខិតទូលថ្វាយព្រះមហាក្សត្ររួច ហើយពីមូលហេតុដែលគណបក្សសម រង្ស៊ី មិនចូលរួមប្រជុំនេះ ដោយការបោះឆ្នោតបានបញ្ចប់ទៅដោយភាពមិនប្រក្រតី ច្រើនទាក់ទិនអ្នកបោះឆ្នោត ហើយ ស្ថាប័ន គជប និងក្រុមប្រឹក្សាធម្មនុញ្ញមិនបានដោះស្រាយបញ្ហាដោយយុត្តិធម៌ ទេ។ល។ និង។ល។ ព្រះមហាក្សត្របានទទួលលិខិតរបស់គណបក្សសម រង្ស៊ី ហើយនៅថ្ងៃទី១២ កញ្ញា តែសំណួរនៅសួរថាតើព្រះមហាក្សត្រ សព្វព្រះទ័យកោះប្រជុំដោយឡែកសំរាប់គណបក្សសម រង្ស៊ីឬទេ?

តែយ៉ាងណាក៏ដោយក៏នៅមានមតិសុទិដ្ឋិនិយមមួយលើកឡើងថា បញ្ហាទាំងអស់នេះនឹងអាចដោះស្រាយចេញ **តាមផ្លូវចរចា ឬសម្បាទាននយោបាយ**ដូចកាលពីអាណត្តិ ទីបីកន្លងទៅពាក់ពន្ធ័នឹងការបង្កើតសភា និងរាជរដ្ឋាភិបាល ដែរ។ តែទោះជាយ៉ាងណាក៏ដោយក៏ **ខុមប្រែល** នឹងនៅតែបន្តតាមដាន និងឃ្លាំមើលលើដំណើរការរៀបចំរដ្ឋសភា ការបើកសម័យប្រជុំដំបូង ការប្រកាសសុពលភាពអ្នកតំណាងរាស្ត្រ និងពិធីធ្វើសច្ចាប្រណិធានចូលកាន់តំណែងរបស់ សមាជិករដ្ឋសភា៕

**អ្នកឃ្លាំមើល**

*តមកពីទំព័រទី៧*

# ការសង្កេតលើដំណើរការប្តឹងតវ៉ាលើលទ្ធផលបណ្តោះ...

គណបក្សនយោបាយ ដោយបានលើកពីមូលហេតុថាអ្នកប្តឹងពុំបានផ្តល់ភស្តុតាងបញ្ជាក់ពីភាពមិនប្រក្រតីដូចមាន ចែងក្នុងមាត្រា១១៤ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដើម្បីឱ្យ **គជប** យកមកពិនិត្យ និងពិចារណាបានឡើយ ។

ក្នុងការទទួលពាក្យបណ្តឹង តំណាង **គជប** បានធ្វើកំណត់ហេតុសួរយកចំលើយបន្ថែមពីតំណាង/មេធាវីរបស់ គណបក្សនយោបាយ ។ ប៉ុន្តែ គជប មិនបានចាត់វិធានការស៊ើបអង្កេតលើភាពមិនប្រក្រតី ឬ/និង ទៅលើឯកសារ ភស្តុតាងដែលគណបក្សនយោបាយបានលើកឡើងនោះទេ ។ **គជប** បានធ្វើសេចក្តីសំរេចបដិសេធពាក្យបណ្តឹងរបស់ គណបក្សនយោបាយដោយកិច្ចប្រជុំសំរេច ហើយមិនបើកសវនាការជាសាធារណៈទេ ដែលបានរំលោភយ៉ាងបំពានលើ ចំណុចទី២៥មាត្រា១៦នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលបានកំណត់ឱ្យ **គជប** ធ្វើការសំរេច ដោយបើកសវនាការជាសាធារណៈលើពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ទាក់ទងនឹងការបោះឆ្នោត ។

ក្នុងសេចក្តីសំរេចបដិសេធរបស់ **គជប** មានយោងអង្គប្រជុំ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៨ នាំឱ្យមាន ការលើកឡើងថា **គជប** បានប្រជុំនៅថ្ងៃ១២ ខែសីហា ឆ្នាំ២០០៨ នេះយ៉ាងណា ដោយសារសេចក្តីសំរេចរបស់ **គជប** នេះបានបញ្ជូនទៅដល់គណបក្សនយោបាយនៅម៉ោង៨ និង៤៥នាទីព្រឹក ខណៈពេលដែលពាក្យបណ្តឹងចុងក្រោយ ដែល **គជប** បានទទួល និងបំពេញសំណុំលិខិតចប់សព្វគ្រប់នៅវេលាម៉ោង១៨និង១០នាទីល្ងាចថ្ងៃទី១១ខែសីហា ឆ្នាំ២០០៨ទៅហើយនោះ ។ ទោះបីបទបញ្ជា និងនីតិវិធីបានចែងពីថ្ងៃធ្វើការរបស់មន្ត្រី បុគ្គលិកគណៈកម្មការរៀបចំការ បោះឆ្នោតគ្រប់លំដាប់ថ្នាក់គឺត្រូវធ្វើទាំងថ្ងៃសៅរ៍ និងអាទិត្យផង លើកលែងតែថ្ងៃបុណ្យជាតិជាផ្លូវការ តែអំពីពេលម៉ោងសំរាប់ធ្វើការជាផ្លូវការក្នុងមួយថ្ងៃនោះនាំឱ្យមានការមន្ទិលសង្ស័យពីការរៀបចំការប្រជុំសំរេចរបស់ **គជប** នេះ និងអំពីនីត្យានុកូលភាពនៃសេចក្តីសំរេចបដិសេធរបស់ **គជប** ផងដែរ ។

ក្នុងពាក្យបណ្តឹងគណបក្សនយោបាយដែលបានលើកឡើងពីបញ្ហានៃភាពមិនប្រក្រតី ការប្រើប្រាស់ទំរង់ ១០១៨ ក្លែងបន្លំដើម្បីបោះឆ្នោតលើឈ្មោះរបស់អ្នកដទៃ **គជប** បានបដិសេធថា ការក្លែងបន្លំឯកសារបញ្ជាក់អត្តសញ្ញាណមិនមែនជាសមត្ថកិច្ចរបស់ គជប ឡើយ ។ ទំរង់ ១០១៨ នេះគឺលិខិតបញ្ជាក់របស់មេឃុំ ចៅសង្កាត់ចេញ ឱ្យប្រជាពលរដ្ឋដើម្បីបញ្ជាក់ពីអត្តសញ្ញាណរបស់ខ្លួនសំរាប់ប្រើប្រាស់ក្នុងការចុះឈ្មោះអ្នកបោះឆ្នោត ។ ហើយទំរង់នេះ **គជប** ជាអ្នកតាក់តែងគំរូហើយបានផ្តល់ជូនដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ នៅទូទាំងប្រទេស ដើម្បីប្រើប្រាស់ ហើយ ផ្នែកខាងលើនៃទំរង់នេះមានរូបសញ្ញាសំគាល់ (Logo) របស់ **គជប** ផង ។ ទោះជាយ៉ាងនេះក្តី **គជប** មិនអាចគ្រប់គ្រង ពីបរិមាណនៃទំរង់នេះ ដែលមេឃុំ ចៅសង្កាត់បានចេញដល់អ្នកបោះឆ្នោតបានឡើយ ។

**៤-ការប្តឹងតវ៉ា និងការសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ**

ក្រោយពី **គជប** បានចេញសេចក្តីសំរេចបដិសេធ គណបក្សនយោបាយចំនួនពីរ គឺគណបក្សសម រង្ស៊ី និង គណបក្សសិទ្ធិមនុស្ស មិនសុខចិត្តនឹងសេចក្តីសំរេចរបស់ **គជប** ហើយបានដាក់ពាក្យបណ្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញទៀត ដែលមានបណ្តឹងចំនួនបីដោយ គណបក្ស សម រង្ស៊ីបានដាក់ពាក្យបណ្តឹងចំនួនពីរច្បាប់ ក្នុងពេលជាមួយគ្នានេះ គណបក្ស នរោត្តម រណឫទ្ធិមិនបានប្តឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញទេ ។

យោងមាត្រា១១៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ក្រុមប្រឹក្សាធម្មនុញ្ញមានពេលវេលា ពី១០ថ្ងៃទៅ ២០ថ្ងៃ ក្នុងការសំរេចដោះស្រាយលើបណ្តឹងតវ៉ានេះ ។

ក្នុងដំណើរការដោះស្រាយ នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៨ ក្រុមប្រឹក្សាធម្មនុញ្ញបានកោះហៅតំណាង គណបក្សសម រង្ស៊ីមកសួរយកចំលើយ និងអាចបន្ថែមភស្តុតាងដាក់បន្ទុក និងតំណាង **គជប** ឱ្យចូលមកបកស្រាយការពារការចេញសេចក្តីសំរេចដោយមិនបើកសវនាការ ដើម្បីបដិសេធពាក្យបណ្តឹងរបស់គណបក្សនយោបាយ ។ ក្នុងការកោះហៅមកបំភ្លឺនេះ ក្រុមប្រឹក្សាធម្មនុញ្ញបានអញ្ជើញតែមេធាវីប៉ុណ្ណោះ ដោយមិនអញ្ជើញប្រធានគណបក្ស នយោបាយចូលមកបំភ្លឺដោយផ្ទាល់ទេ ។ នៅថ្ងៃនោះផងដែរ លោក សម រង្ស៊ីក៏មានវត្តមាននៅខាងក្រៅក្រុមប្រឹក្សាធម្មនុញ្ញផងដែរ ប៉ុន្តែមិនត្រូវបានអនុញ្ញាតឱ្យចូលក្នុងបន្ទប់សាកសួរឡើយ គឺអនុញ្ញាតតែមេធាវីតែម្នាក់គត់ ។ បញ្ហានេះនាំឱ្យមានការសង្ស័យ ពីការដែលក្រុមប្រឹក្សាធម្មនុញ្ញមិនអញ្ជើញប្រធានគណបក្សនយោបាយមកបំភ្លឺដោយផ្ទាល់ ទោះបីជាមានលិខិតសុំពឹងពាក់មេធាវីយ៉ាងណាក៏ដោយ ។ ចំពោះការសួរយកចំលើយ និងការរកភស្តុតាងដាក់បន្ទុក បន្ថែមពីគណបក្សនយោបាយ តាមការសង្កេតរកឃើញថាមានភាពមិនច្បាស់លាស់ក្នុងការអនុវត្តនីតិវិធីនេះ ដោយគ្រាន់តែអញ្ជើញមេធាវីឱ្យចូលរមកបំភ្លឺ ប៉ុន្តែ ថ្នាក់ដឹកនាំគណបក្សសម រង្ស៊ីជាតំណាងផ្ទាល់មិនត្រូវបានអនុញ្ញាត ឱ្យចូលរួមក្នុងនីតិវិធី

នេះទេ។

ចំណែកនៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៨ ក្រុមប្រឹក្សាធម្មនុញ្ញបានអញ្ជើញតំណាងគណបក្សសិទ្ធិមនុស្ស ឱ្យចូលមកបំភ្លឺបន្ថែម ចំពោះមុខក្រុមប្រឹក្សាធម្មនុញ្ញ និងអាចលើកភស្តុតាងដាក់បន្ទុកបន្ថែម។

រយៈពេលតែ៦ថ្ងៃក្រោយមក បន្ទាប់ពីការអញ្ជើញមេធាវី ឬតំណាងឱ្យចូលមកបំភ្លឺលើកភស្តុតាងដាក់បន្ទុកបន្ថែម (នៅថ្ងៃទី២៦-២៧-២៨ ខែសីហា ឆ្នាំ២០០៨) ក្រុមប្រឹក្សាធម្មនុញ្ញបានបើកសវនាការជាសាធារណៈ ដើម្បីដោះស្រាយពាក្យបណ្តឹងទាំងបីនេះ។ ក្នុងដំណើរការសវនាការ គឺអង្គជំនុំជំរះនៃក្រុមប្រឹក្សាធម្មនុញ្ញបានបើកចំហ ដល់តំណាងគណបក្សនយោបាយ និងតំណាង **គជប** ក្នុងការឆ្លើយបំភ្លឺចំពោះមុខអង្គជំនុំជំរះ។ ប៉ុន្តែ ចុងក្រោយ ក្រុមប្រឹក្សាធម្មនុញ្ញបានចេញសេចក្តីសំរេចបដិសេធបណ្តឹងទាំងអស់របស់គណបក្សនយោបាយ ហើយដំកល់សេចក្តីសំរេច របស់ គជប ទុកជាបានការពេញទាំងមូល។ ការសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញមិនបានពិនិត្យមើលលើនីត្យានុកូលភាព នៃសេចក្តីសំរេចរបស់ **គជប** ដែលមិនបានបើកសវនាការ និងមិនអនុវត្តត្រឹមត្រូវតាមបទបញ្ញត្តិនៃចំណុចទី២៥នៃ មាត្រា១៦ មាត្រា១១១ ១១២ ១១៤ និង១១៥ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការខ្វះការ ទទួលខុសត្រូវក្នុងការស៊ើបអង្កេតបន្ថែមឡើយ។

នៅចំពោះមុខអង្គជំនុំជំរះរបស់ក្រុមប្រឹក្សាធម្មនុញ្ញ តំណាង **គជប** បានធ្វើការអះអាងពីមូលហេតុនៃការធ្វើ សេចក្តីសំរេចបដិសេធថា គណបក្សនយោបាយមិនបានបង្ហាញពីភាពមិនប្រក្រតីជាក់លាក់នៃការប្រព្រឹត្តខុសរបស់ គណៈកម្មការបោះឆ្នោតពីពេលវេលា ទីកន្លែង និងភស្តុតាងដែលបញ្ជាក់ពីភាពមិនប្រក្រតីឡើយ។ ចំពោះការ លើកឡើងរបស់គណបក្សនយោបាយខាងលើ តំណាង **គជប** បានធ្វើការបកស្រាយដូចខាងក្រោម :

១- ការលុបឈ្មោះអ្នកបោះឆ្នោត ការបំប៉ោងតួលេខ និងបន្ថែមឈ្មោះស្ទួនក្នុងបញ្ជីបោះឆ្នោត

បញ្ហាពាក់ព័ន្ធនឹងបញ្ជីឈ្មោះអ្នកបោះឆ្នោតគឺមិនអាចតវ៉ា និងដោះស្រាយបាននៅពេលនេះទេ (ដំណាក់កាលដោះស្រាយបណ្តឹងតវ៉ាលើលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត)។ ក្នុងការធ្វើបច្ចុប្បន្នភាព ការចុះឈ្មោះអ្នកបោះឆ្នោត និងសំអាតបញ្ជីបោះឆ្នោតនោះគឺ **គជប** បានរៀបចំតាមនីតិវិធី ហើយទុកពេល ជូនប្រជាពលរដ្ឋធ្វើការប្តឹង តវ៉ាបាន។

២- ការផ្លាស់ប្តូរការិយាល័យបោះឆ្នោតខុសពីទីតាំងដើម និងការរកឈ្មោះក្នុងបញ្ជីមិនឃើញ

**គជប** បានបញ្ជាក់ថាក្នុងការិយាល័យបោះឆ្នោតមួយត្រូវមានអ្នកបោះឆ្នោតយ៉ាងច្រើនត្រឹម៧០០នាក់។ ក្នុងករណីដែលស្មៀនឃុំ សង្កាត់បានចុះឈ្មោះលើសពី៧០០នាក់ គឺត្រូវបំបែកជា២ការិយាល័យភ្លោះ ហើយត្រូវបានរៀបចំ ឱ្យនៅទីតាំងក្បែរគ្នា។

៣- ការបោះឆ្នោតជំនួសដោយអ្នកដែលគ្មានសិទ្ធិបោះឆ្នោតហើយបោះលើឈ្មោះអ្នកដទៃ

ចំពោះការបោះឆ្នោតជំនួស តំណាង **គជប** បានធ្វើការបដិសេធថា ក្នុងចំណោមអ្នកបោះឆ្នោតដែលគណបក្ស នយោបាយលើកឡើងជាសំអាងថាមិនបានបោះឆ្នោតដោយមានអ្នកបោះជំនួសនោះគឺភាគច្រើនមិនមានឈ្មោះក្នុងបញ្ជី បោះឆ្នោតទេ។ តែតំណាង **គជប** បានទទួលស្គាល់ថាមានករណីបោះឆ្នោតលើឈ្មោះអ្នកដទៃចំនួន១ករណី នៅភ្នំពេញ ហើយបានដោះសារជា **កំហុសដោយអចេតនា**។

៤-ការចេញទំរង់ ១០១៨ នៅថ្ងៃបោះឆ្នោត ដោយខុសនឹងបទបញ្ជា និងនីតិវិធី

មេឃុំ ចៅសង្កាត់ដែលបានចេញទំរង់ ១០១៨ នៅថ្ងៃបោះឆ្នោត ដែលគណបក្សនយោបាយមានភស្តុតាង ហើយ **គជប** ធ្វើការស៊ើបអង្កេតបន្ថែមថាមានមែននោះគឺ **គជប** បានស្នើទៅក្រសួងមហាផ្ទៃដើម្បីដាក់វិន័យរដ្ឋបាលរួចហើយ។ រីឯការចេញទំរង់ ១០១៨ ក្លែងបន្លំ **គជប** បានបដិសេធថាមិនស្ថិតក្នុង**សមត្ថកិច្ច**របស់ **គជប** ទេ។

បញ្ហានេះនាំឱ្យមានមន្ទិលសង្ស័យលើការបកស្រាយរបស់ថាគ្មាន "ភស្តុតាងគ្រប់គ្រាន់" ប៉ុន្តែ **គជប** មិនពិនិត្យ ពិចារណាលើភស្តុតាង និងឯកសារនានាដែលគណបក្សនយោបាយលើកជូនក្នុងពាក្យបណ្តឹទេ។ ឧទាហរណ៍ ភាពមិន ប្រក្រតីនៃទំរង់ ១០១៨ មួយចំនួនដែលគណបក្សនយោបាយលើកឡើងគឺបានបញ្ជាក់យ៉ាងច្បាស់បំផុតពីការក្លែងបន្លំ និងការបំពេញបែបបទដោយខុសនីតិវិធីទាំងស្រុង។

**ជាសរុប** អាទិភាពក្នុងការកែលំអដំណើរការប្តឹងតវ៉ាលើលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតគឺត្រូវពិនិត្យ មើលឡើងវិញពីយន្តការ និងក្របខ័ណ្ឌច្បាប់ ដែលគណបក្សនយោបាយ **គជប** ក្រុមប្រឹក្សាធម្មនុញ្ញ ភាគីពាក់ព័ន្ធ និង អ្នកឯកទេសជំនាញគួរជជែកពិភាក្សាឡើងវិញ ពីលទ្ធភាពក្នុងការធ្វើវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំង តំណាងរាស្ត្រដើម្បីរៀបចំ ក្របខ័ណ្ឌ

ច្បាប់សំរាប់កំណត់អំពីស្ថាប័ន អំពីពេលវេលាស្របច្បាប់សមរម្យ នីតិវិធីក្នុងការ ដាក់/ទទួលពាក្យបណ្តឹង ការសួរយកព័ត៌មានបន្ថែម ការស៊ើបអង្កេតជាក់ស្តែង នីតិវិធីសវនាការ និងការធ្វើសេចក្តី សំរេចលើវិវាទស្តីពីលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រយ៉ាងមានសារៈសំខាន់នេះ ។

តមកពីទំព័រទី១៣

## លទ្ធផលនៃការបោះឆ្នោត២០០៨ និងប្រព័ន្ធបោះ....

| | |
|---|---|
| - គណបក្សប្រជាជនកម្ពុជាទទួលបាន | ៧២ អាសនៈ |
| - គណបក្សសម រង្ស៊ីទទួលបាន | ២៧ អាសនៈ |
| - គណបក្សសិទ្ធិមនុស្សទទួលបាន | ៨ អាសនៈ |
| - គណបក្សនរោត្តម រណឫទ្ធិទទួលបាន | ៧ អាសនៈ |
| - គណបក្សហ៊្វុនស៊ិនប៉ិចទទួលបាន | ៦ អាសនៈ |
| - គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យទទួលបាន | ១ អាសនៈ |
| - គណបក្សប្រជាធិបតេយ្យខ្មែរទទួលបាន | ១ អាសនៈ |
| - គណបក្សហង្ស ដារ៉ាចលនាប្រជាធិបតេយ្យទទួលបាន | ១ អាសនៈ ។ |

ករណីនេះ ចំនួនអាសនៈដែលគណបក្សនយោបាយទទួលបានគឺសមាមាត្រនឹងចំនួនសន្លឹកឆ្នោតដែលប្រជាពលរដ្ឋបានបោះឱ្យ ឬអាចនិយាយថាប្រព័ន្ធនេះតំណាងឱ្យសំលេងរបស់អ្នកបោះឆ្នោតបានយុត្តិធម៌ច្រើនជាងប្រព័ន្ធ ដែលត្រូវបាននិងកំពុងអនុវត្តបច្ចុប្បន្ន។ យើងឃើញថា ការអនុវត្តរូបមន្តដូចឆ្នាំ១៩៩៣នោះគឺធ្វើឱ្យគណបក្សចំនួន បីទៀតទទួលបានអាសនៈក្នុងរដ្ឋសភាចំនួន១អាសនៈ គឺ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ គណបក្សប្រជាធិបតេយ្យខ្មែរ និងគណបក្សហង្សដារ៉ាចលនាប្រជាធិបតេយ្យ ។

ជាមួយនឹងបញ្ហាប្រព័ន្ធបោះឆ្នោតបច្ចុប្បន្ននេះដែរឃើញថា គណបក្សនយោបាយដែលត្រូវបានគេបំបែក ឬ បែកបាក់ខ្លួនឯង ដោយបង្កើត គណបក្សនយោបាយផ្សេងៗជាច្រើននោះធ្វើឱ្យខាតបង់សំលេងឆ្នោតច្រើន ហើយ នឹងអាចចាញ់ ឬក៏មិនបានទទួលអាសនៈក្នុងរដ្ឋសភាទេ បើទោះបីគណបក្សដែលបែកបាក់នោះមានលទ្ធផលបោះឆ្នោត បូកចូលគ្នាស្មើនឹងលទ្ធផលពេលមិនទាន់បែកបាក់ក៏ដោយ ។ ឧទាហរណ៍ដូចជាគណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្ស នរោត្តមរណ ឫទ្ធិ បានទទួលសន្លឹកឆ្នោតរួមគ្នាបាន ៥០%នៃលទ្ធផលបោះឆ្នោតរបស់គណបក្សហ៊្វុនស៊ិនប៉ិច កាលពីឆ្នាំ ២០០៣ក៏ដោយ ប៉ុន្តែគណបក្សទាំងពីរនៅឆ្នាំ២០០៨នេះទទួលបានអាសនៈតែបួនប៉ុណ្ណោះ គឺម្នាក់ៗតែ២អាសនៈមិនមែន ១៣អាសនៈដែលស្មើនឹង២៦អាសនៈចែកជាពីរនោះឡើយ(កាលពីឆ្នាំ២០០៣ ហ៊្វុនស៊ិនប៉ិច ទទួលបាន ២៦ អាសនៈ) ។ ម្យ៉ាងទៀត ដោយសារបច្ចេកទេសនៃប្រព័ន្ធបោះឆ្នោត ដែលច្បាប់បោះឆ្នោតកម្ពុជាយើងកំណត់យកប្រព័ន្ធសមាមាត្រតាមខេត្ត ក្រុង និងរូបមន្តមធ្យមភាគខ្ពស់បំផុតផងនោះ ធ្វើឱ្យគណបក្សកាន់តែខាតបង់សំលេងឆ្នោត ដោយសារការបំបែកជាគណបក្សតូចៗនេះ។ ផ្ទុយទៅវិញ ប្រសិនបើគណបក្សដែលទទួលបានសំលេងឆ្នោតតិចព្យាយាមរួម បញ្ចូលគ្នាមុនដំណើរការបោះឆ្នោតនោះ ធ្វើឱ្យពួកគេចំណេញអាសនៈច្រើនជាងអ្វីដែលពួកគេបានទទួលរៀងៗខ្លួននោះ ។ជាក់ស្តែងយើងសាកល្បងសិក្សាលើលទ្ធផលដដែល នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៨នេះ ហើយឧបមាថា យកសំលេងឆ្នោតរបស់គណបក្សនយោបាយ ចំនួន៤ បូកបញ្ចូលគ្នា (គណបក្សសម រង្ស៊ី គណបក្ស សិទ្ធិមនុស្ស គណបក្ស នរោត្តម រណឫទ្ធិ និងគណបក្ស ហ៊្វុនស៊ិនប៉ិច) ហើយគណនាដោយប្រព័ន្ធបោះឆ្នោត ដដែល គឺប្រព័ន្ធសមាមាត្រ ដោយយកខេត្ត ក្រុងធ្វើមណ្ឌល បោះឆ្នោត ជាមួយនឹងរូបមន្តមធ្យមភាគខ្ពស់បំផុត ធ្វើឱ្យលទ្ធផលមានការប្រែប្រួល គឺគណបក្សប្រជាជនកម្ពុជាទទួលបានតែ៧៧អាសនៈ ហើយសម្ព័ន្ធភាពបួនគណបក្ស ទទួលបាន៤៦អាសនៈក្នុងរដ្ឋសភា ហើយដែលពេលនេះអាសនៈដែលគណបក្សទាំងបួនទទួលផ្សេងពីគ្នារៀងៗ ខ្លួន នោះសរុបគឺបានតែ៣៣អាសនៈប៉ុណ្ណោះ ។

តាមការសិក្សាខាងលើបង្ហាញថា ការរួបរួមគ្នារវាងបណ្តាគណបក្សភាគតិចមិនកាន់អំណាច និងការកែទំរង់ ប្រព័ន្ធបោះឆ្នោតធ្វើឱ្យគណបក្សតូចៗមានផលចំណេញច្រើនទាំងខាងនយោបាយ និងបច្ចេកទេស ប្រសើរជាងការ ព្យាយាមបំបែក ឬបង្កើតជាគណបក្សនយោបាយផ្សេងៗជាច្រើននោះ ។

ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ នេះគ្រាន់តែជាការសិក្សាជាលក្ខណៈទ្រឹស្តី និងមានលក្ខណៈបច្ចេកទេសសុទ្ធសាធតែប៉ុណ្ណោះ ។ នៅលើពិភពលោកនេះ គេមិនទាន់ឃើញមានអ្នកជំនាញឯកទេសណាអះអាងពីគុណសម្បត្តិភាព យុត្តិធម៌ ភាពសុក្រឹតល្អឥត

ខ្មែរនៃប្រព័ន្ធបោះឆ្នោតណាមួយឡើយ ។ដើម្បីបង្កើនយុត្តិធម៌ និងប្រជាធិបតេយ្យ ប្រទេស ភាគច្រើនបានកែទំរង់ ហើយជ្រើសរើសយកប្រព័ន្ធចំរុះដូចជាឯកត្តនាម និងបញ្ជីគណបក្សផង ។ នៅក្នុងប្រទេស នីមួយៗ ការជ្រើសរើសយក ប្រព័ន្ធចំរុះមួយណាមកអនុវត្តនោះ វាអាស្រ័យលើការសំរេចចិត្តរបស់អ្នកនយោបាយ ហើយអាស្រ័យលើបរិបទនៃប្រទេស នីមួយៗ ភាពចាស់ទុំខាងប្រជាធិបតេយ្យ ជាដើម ។

សំរាប់កម្ពុជា អនុសាសន៍បឋម យ៉ាងហោចណាស់ក្នុងខេត្ត ក្រុងចំនួន៩ ដែលមានអាសនៈតែមួយនោះគឺគួរ បោះឆ្នោតតាមប្រព័ន្ធភាគច្រើននិយមដោយបញ្ជី ដែលបញ្ជីបេក្ខជនមកពីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឯករាជ្យ មិនមែនគណបក្សនយោបាយអាចចូលប្រកួតប្រជែងបានដូចគ្នា ឬប្រើប្រព័ន្ធឯកត្តនាមតែម្តង៕

**ដោយ ការ៉ង អេន**

# កាលប្បវត្តិព្រឹត្តិការណ៍សំខាន់ៗ ពីខែ មិថុនា ដល់ខែសីហា ២០០៨

***នយោបាយ និងប្រជាធិបតេយ្យ***



- **២៥ មិថុនា :** សម្តេចនរោត្តម សេរីវុឌ្ឍ សមាជិកសភាគណបក្សហ៊្វុនស៊ិនប៉ិចនិងជាអតីតសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានប្រកាសថា ព្រះអង្គបានលាលែងពីជីវិតនយោបាយហើយ ។
- **២៣ មិថុនា :** ប្រទេសកម្ពុជាបិទច្រកព្រំដែននៅឯប្រាសាទព្រះវិហារជាឯកតោភាគីគ្នានៅចំងាយ ៣០០ ម៉ែត្រ ពីប្រាសាទ ជាប់ព្រំដែន ក្រោយពីមានចលនាបាតុកម្មរបស់ជនជាតិថៃនៅតំបន់ក្បែរប្រាសាទព្រះវិហារ ។ តែនៅថ្ងៃ **២៨ មិថុនា :** តុលាការរដ្ឋបាលថៃក៏បានចេញបញ្ជាឱ្យគណៈរដ្ឋមន្ត្រីថៃ ឈប់គាំទ្រការដាក់បញ្ចូលប្រាសាទ ព្រះវិហារ និងឈប់ គាំទ្រផែនទីដែលភាគីកម្ពុជាគូរសំរាប់ដាក់បញ្ចូលប្រាសាទ ព្រះវិហារទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ។ ដោយឡែកក្រសួងការបរទេសថៃបាននិយាយថា ខ្លួននឹងប្តឹងឧទ្ធរណ៍ចំពោះការសំរេចរបស់តុលាការរដ្ឋបាល នោះទៅកាន់ តុលាការរដ្ឋបាលកំពូលទៀតដើម្បីវិនិច្ឆ័យការសំរេចនេះ ។ ទោះជាយ៉ាងណានៅថ្ងៃទី**០៨ កក្កដា :** ប្រាសាទព្រះវិហារ ត្រូវបានអនុម័តជាឯកឆន្ទចុះបញ្ជីបតិកភណ្ឌពិភពលោកក្នុងសម័យប្រជុំលើកទី៣២ នៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោកនៅទីក្រុង**កេបិច** ប្រទេស**កាណាដា** ។ ហើយប្រាសាទព្រះវិហារ បានក្លាយជា ទីតាំងថ្មីមួយចំណោម ទីតាំង ថ្មី១៣កន្លែងដែលត្រូវបានការពារ ក្រោមបញ្ជីបេតិកភណ្ឌពិភពលោក និងត្រូវបានឧបត្ថម្ភឱ្យកម្ពុជាប្រើប្រាស់ទឹកប្រាក់៤លានដុល្លារក្នុងមូលនិធិបេតិភណ្ឌពិភពលោកទុកសំរាប់រក្សាការពារ និងអភិវឌ្ឍន៍ ។ នៅថ្ងៃ**១៥ កក្កដា :** ភាព តានតឹងបានកើតឡើងគួរឱ្យ ព្រួយបារម្ភបានកើតឡើងនៅ ប្រាសាទព្រះវិហារ ខណៈពេលដែលប៉ូលីសកម្ពុជាបានចាប់ខ្លួនអ្នកតវ៉ាថៃ ៣នាក់ ដែលបាន ចូលក្នុងតំបន់ប្រាសាទនេះ ហើយក្រោយមកទាហាន ថៃ ជាង១០០នាក់ ចូលមកអែប ទឹកដីដែលកាន់កាប់ដោយកម្ពុជា ដើម្បីចរចាសុំដោះលែងពួកគេវិញ ។ បន្ទាប់មកក៏មានការប្រជុំជាទ្វេភាគីរវាងរដ្ឋមន្ត្រីការពារជាតិកម្ពុជា និងថៃនៅ ថ្ងៃទី២១ ខែកក្កដា ២០០៨ នៅខេត្តស្រះកែវ ប្រទេសថៃ នៅថ្ងៃទី២៨ កក្កដា ឆ្នាំ២០០៨ ថ្នាក់រដ្ឋមន្ត្រី ការបរទេស នៅខេត្តសៀមរាបប្រទេសកម្ពុជា និងនៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៨ នៅហួរហ៊ិនប្រទេសថៃ តែគួរកត់សំគាល់ថា ជាលទ្ធផលនៅមិនទាន់បានជាដុំកំភួននៅឡើយហើយការចរចានៅតែមានគំរោងបន្ត ។ ទន្ទឹមគ្នានេះដែរយោធាសៀមបាន បន្តចូលទន្ទ្រានកាន់កាប់តំបន់ប្រាសាទ តាមាន់តូច តាមាន់ធំនៅក្នុងតំបន់ព្រំដែនខេត្តឧត្តរមានជ័យនិងព្រះវិហារបន្ថែមទៀត ។
- **៣០ មិថុនា :** ព្រះរាជសាររបស់អតីតព្រះមហាក្សត្រ នរោត្តម សីហនុ នាពេល ថ្មីៗនេះបានមានបន្ទូលថា រដ្ឋធម្មនុញ្ញ



របស់ប្រទេសកម្ពុជា មិនមែនជាឧបសគ្គចំពោះការលុបបំបាត់រាជានិយមទេ ។ ការគាំរាមមិនចេញឈ្មោះចំពោះ រាជានិយម បានធ្វើឱ្យព្រះអង្គពិចារណាស្វែងរកសិទ្ធិជ្រកកោន នយោបាយនៅក្រៅប្រទេស ។

- **០៣ សីហា** : សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានរំលឹកលោក **សម រង្ស៊ី** មេដឹកនាំគណបក្សប្រឆាំង នៅឯព្រលាន យន្តហោះ ពីការធ្វើពហិការសម័យប្រជុំសភាលើកដំបូងក្រោយការបោះឆ្នោត ដោយមានប្រសាសន៍ថា ប្រសិនបើ គណបក្ស ប្រឆាំងខកខានមិនបានឱ្យសមាជិកសភារបស់ខ្លួនស្បថ ចូលកាន់តំណែងទេនោះ គណបក្សទាំងនោះអាចបាត់ បង់អាសនៈ របស់ខ្លួន ដោយសារតែច្បាប់បានចែងឱ្យមានការជំនួសករណីបែបនេះ ។

## សិទ្ធិមនុស្ស

- **០២ កក្កដា** : ស្ថានទូតវៀតណាម បានអះអាងថា លោក **ទីម សាខន** ដែលជាព្រះសង្ឃខ្មែរកម្ពុជាក្រោម ជាប់ពន្ធនាគារនៅប្រទេសវៀតណាមនោះ ត្រូវបានដោះលែងឱ្យមានសេរីភាពវិញហើយ ក្រោយពីជាប់ទោសរយៈពេល ១ឆ្នាំ ពីបទធ្វើឱ្យខូចពីសាមគ្គីភាពរវាងប្រទេសវៀតណាម និងប្រទេសកម្ពុជា ។ ទោះជាយ៉ាងណាលោក **ទីម សាខន** ដែលកាលពីឆ្នាំមុន ត្រូវបានដកពីតួនាទីជាព្រះចៅអធិការវត្តមួយនៅក្នុងខេត្តតាកែវ ហើយក្រោយមកត្រូវនិរទេសទៅប្រទេសវៀតណាម ជាទីដែលគាត់ត្រូវឃុំខ្លួននោះ មិនទាន់បានវិលត្រលប់មកប្រទេសកម្ពុជាវិញនោះទេ ។
- **០៧ កក្កដា** : យោងតាមរបាយការណ៍សិទ្ធិមនុស្សអាដហុកកាលពីពេលថ្មីៗនេះ បានឱ្យដឹងថា មានការថយចុះករណីរំលោភ ចាប់ពីខែមករា រហូតដល់ខែឧសភាឆ្នាំ ២០០៨ បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នានេះក្នុងឆ្នាំ ២០០៧ ប៉ុន្តែថាការចាប់រំលោភនេះ នៅតែមានកើតឡើងដដែល ។
- **១១ កក្កដា** : អំពើបាញ់ប្រហារមួយបានធ្វើឱ្យអ្នកយកព័ត៌មានកាសែត មនសិការ ដែលមាននិន្នាការប្រឆាំងរដ្ឋាភិបាល លោក **ឃឹម សម្បូរណ៍** និងកូនប្រុសរបស់លោកដែលជិះម៉ូតូ ចេញពីហាត់ប្រាណក្នុងស្តាតអូឡាំពិក បានធ្វើឱ្យ ឪពុកស្លាប់នៅនឹងកន្លែងកើតហេតុ និងកូនរបស់លោកបានស្លាប់ក្រោយពេលដឹកទៅដល់មន្ទីរពេទ្យព្រះកេតុមាលា ។

## ប្រព័ន្ធយុត្តិធម៌



- **២២ មិថុនា** : លោក **ងួន ញ៉ិល** អនុប្រធានទី១នៃរដ្ឋសភា បានមានប្រសាសន៍ ថា តុលាការក្រុងភ្នំពេញនឹងត្រូវតែ រង់ចាំរហូតដល់ក្រោយការបោះឆ្នោតជាតិ ទាក់ទងនឹងការដកអភ័យឯកសិទ្ធិលោក **សម រង្ស៊ី** ប្រធានគណបក្ស សមរង្ស៊ី ។ យោងតាមលិខិតមួយច្បាប់ដែលចុះការបរិច្ឆេទថ្ងៃទី១៦ ខែមិថុនា តុលាការនេះបានស្នើឱ្យដកអភ័យឯក សិទ្ធិលោក **សម រង្ស៊ី** បណ្តោះអាសន្ន ខណៈពេលដែលបណ្តឹងបរិហារកេរ្តិ៍ ផ្សាយពិតមានមិនពិតពីសំណាក់លោក ហោ ណាំហុង រដ្ឋមន្ត្រី ក្រសួងការបរទេស ។



- **២៧ មិថុនា** : លោក **ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិបានថ្លែងថា លោកនឹងសរសេរលិខិតទៅតុលាការក្រុងភ្នំពេញដើម្បីដកពាក្យបណ្តឹង ដែលប្តឹងលោក **ដាំ សិទ្ធិ** និពន្ធ នាយកកាសែតមនសិការខ្មែរវិញ បន្ទាប់ពីលោក **ដាំ សិទ្ធិ** បានជួបលោកកាលពីពេលថ្មីកន្លងទៅនេះ ។
- **០៩ កក្កដា** : ក្រុមចៅក្រមនៃអង្គបុរេជំនុំជំរះសាលាក្តីខ្មែរក្រហម បានសំរេចប្រកាសសាលដីកាបន្ត ឃុំខ្លួន **អៀង ធីរិទ្ធ** អតីតរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនៃរបបខ្មែរក្រហម ក្រោមបទចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ បន្ទាប់ពី តុលាការបានជុំនំជម្រះកាលពីថ្ងៃ២១ មេសា ឆ្នាំ២០០៨ កន្លងទៅដោយ

ការសំរេចចិត្តរបស់ចៅក្រមចំនួន៥រូប ។

**ការបោះឆ្នោត**

    

- **២៦ មិថុនា** : សេរីភាពនៃគណបក្សនយោបាយនានាចាប់ផ្តើម ធ្វើយុទ្ធនាការឃោសនារកសំលេងគាំទ្រ សំរាប់ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រអណ្តតិទី៤នេះ សកម្មភាពឃោសនាមានសណ្តាប់ធ្នាប់គ្រាន់បើនៅទូទាំងប្រទេស ប៉ុន្តែ មានការស្ទះចរាចរណ៍បន្តិចបន្តួច ។ គណបក្សនយោបាយនានា បានធ្វើសកម្មភាពឃោសនារបស់ខ្លួននៅតាមបណ្តាខេត្តក្រុង យ៉ាងអធិកអធមធ្វើឱ្យមានការព្រួយបារម្ភខ្លះៗអំពីស្ថិរភាពអ្នកនយោបាយ ប៉ុន្តែទោះជាយ៉ាងណាមេដឹកនាំធុរកិច្ច មួយចំនួនធំនិយាយថា ពួកគេមិនមានព្រួយបារម្ភខ្លាចចំពោះការបោះឆ្នោតនេះទេ ។
- **០២ កក្កដា** : មន្ត្រីរដ្ឋាភិបាល និងក្រុមមន្ត្រីរៀបចំការបោះឆ្នោតបានព្រមាន មេឃុំ និងមេភូមិមិនឱ្យ ប្រកាន់បក្សពួកក្នុងអំឡុង និងក្រោយការបោះឆ្នោតជាតិនាថ្ងៃ ២៧ ខែកក្កដា ។
- **០៥ កក្កដា** : គណបក្ស**នរោត្តមរណឫទ្ធិ** និងគណបក្ស**សមរង្ស៊ី** បានចោទប្រកាន់ គណបក្ស**ប្រជាជនកម្ពុជា** ពីការប្រើប្រាស់សន្លឹកឆ្នោតគំរូឃោសនាទាក់ទាញប្រជាពលរដ្ឋឱ្យគូសលើសន្លឹកឆ្នោតគំរូនោះ ប៉ុន្តែមន្ត្រីជាន់ខ្ពស់នៃ **គជប** អះអាងថា" មិនខុសច្បាប់ទេ" ពីព្រោះសន្លឹកឆ្នោតគំរូនេះ **គជប** បានចេញឱ្យគ្រប់គណបក្សនយោបាយអង្គការមិនមែនរដ្ឋាភិបាល និងបណ្តាញសារព័ត៌មានឱ្យយកទៅផ្សព្វផ្សាយជាសាធារណៈ ។
- **០៨ កក្កដា** : គណបក្សចំនួន១០ ក្នុងចំណោម១១ ដែលប្រកួតប្រជែងក្នុងការ បោះឆ្នោតជាតិនានាបាន សន្យាជាសាធារណៈ ថានឹងអនុម័តច្បាប់ប្រឆាំងអំពើពុករលួយក្នុងរយៈពេល៦ខែ ដំបូងនៅពេលជាប់ឆ្នោត ។
- **០៧ សីហា** : ក្រុមអ្នកតំណាងមកពីគណបក្ស សម រង្ស៊ី គណបក្សសិទ្ធិមនុស្ស និងគណបក្ស **នរោត្តមរណឫទ្ធិ** បានជួបប្រជុំគ្នាបង្កើតគណៈកម្មាធិការរួមមួយ ដើម្បីពិភាក្សាលទ្ធភាពនៃការបង្កើតសម្ព័ន្ធភាពរវាងបក្សទាំង៣ ។ តែនៅ ថ្ងៃទី **១២ សីហា** : គណបក្ស**នរោត្តមរណឫទ្ធិ** បានដកខ្លួនចេញពីគណបក្ស**សមរង្ស៊ី** និងគណបក្ស**សិទ្ធិមនុស្ស** ដែលទើបតែចងសម្ព័ន្ធភាពថ្មីៗប្រឆាំងនឹងលទ្ធផលបោះឆ្នោតហើយវិលទៅរកការគាំទ្រវិញ ។ ព្រះអង្គម្ចាស់**នរោត្តមរណឫទ្ធិ** ប្រធានគណបក្សនរោត្តមរណឫទ្ធិ ដែលបាននិរទេសដោយព្រះអង្គឯងនោះ បានចេញសេចក្តីថ្លែងការណ៍មួយថាឥឡូវនេះគណបក្ស របស់ព្រះអង្គទទួលស្គាល់លទ្ធផលបោះឆ្នោតនេះ ។
- **០៩ សីហា** : គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានប្រកាសលទ្ធផលបណ្តោះអាសន្នហើយ នាថ្ងៃ០៩ ខែសីហា ដោយមិនទាន់បានគិតគូរពីចំនួនអាសនៈសំរាប់គណបក្សនីមួយៗនៅឡើយទេ ក៏ប៉ុន្តែបើប្រៀបធៀបទៅនឹងលទ្ធផលបឋម ដែលប្រភពឯករាជ្យនានាផ្សាយកន្លងមកឃើញថា ចំនួនសំលេងគាំទ្រមានការប្រែប្រួលខុស-ពីការប៉ាន់ស្មានរបស់ អ្នកសង្កេតការណ៍ខ្លះ តែមិនធ្វើឱ្យលទ្ធផលផ្លាស់ប្តូរឡើយ ពោលគឺគណបក្សប្រជាជនកម្ពុជាទទួលបាន ៩០អាសនៈ គណបក្ស សមរង្ស៊ីទទួលបាន២៦អាសនៈ គណបក្សសិទ្ធិមនុស្សទទួលបាន៣អាសនៈ គណបក្សហ្វ៊ុនស៊ិនប៉ិច ២អាសនៈ និងគណបក្ស នរោត្តមរណឫទ្ធិបាន ២អាសនៈ ។ **១២ សីហា** : អង្គការសង្គមស៊ីវិលចំរុះបានអំពាវនាវឱ្យ មានការកែទំរង់គណៈកម្មាធិការ ជាតិរៀបចំការបោះឆ្នោត ដើម្បីទប់ស្កាត់ភាពមិនប្រក្រតីក្នុងការបោះឆ្នោតនាពេល អនាគត ដែលពួកគេនិយាយថា **គជប** បានធ្វើឱ្យខូច ទ្រង់ទ្រាយខ្លះនាការបោះឆ្នោតកាលពីថ្ងៃទី ២៧ ខែកក្កដា ។ ក្រុមអង្គការសង្គមស៊ីវិលនោះ បាននិយាយ ថាយន្តការដោះស្រាយបណ្តឹង និងជំលោះនៃការបោះឆ្នោតរបស់ **គជប** ត្រូវ តែផ្លាស់ប្តូរទំរង់១០១៨ ហើយ ច្បាប់ថ្មីស្តីពីហិរញ្ញវត្ថុគណបក្សនយោបាយគួរត្រូវបានបង្កើតឡើង ។

***សេដ្ឋកិច្ច***

- **០១ កក្កដា** : សេដ្ឋវិទូ នឹងអ្នកដឹកនាំឧស្សាហកម្ម និងសហជីពបាននិយាយថា ការប្រកួតប្រជែងដ៏មានសក្តានុពលពីប្រទេសចិន និងអតិផរណាឡើងខ្ពស់ កំពុងតែគំរាមកំហែងឧស្សាហកម្ម កាត់ដេរនៅប្រទេសកម្ពុជា ។
- **០៥ កក្កដា** : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឱ្យដឹងថា បន្ទាប់ពីបានចុះហត្ថលេខាលើអនុស្សរណៈ យោគយល់ជាមួយធនាគារ **BUSAN** របស់កូរ៉េសំរាប់ការជួយអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ បំរើឱ្យការបង្កើតទីផ្សារមូលបត្រ នៅកម្ពុជាមក ក្រសួងនៅបានចុះហត្ថលេខាមួយ បន្ថែមទៀតជាមួយ គណៈកម្មការសេវាកម្មហិរញ្ញវត្ថុកូរ៉េ FSC ដែលជាអាជ្ញាធរវិស័យហិរញ្ញវត្ថុទទួលបន្ទុករួមទាំងវិស័យមូលបត្រផងដែរ ។

# ការបោះឆ្នោតនៅប្រទេសនេប៉ាល់ឆ្នាំ២០០៨

ប្រទេសនេប៉ាល់ ស្ថិតនៅទ្វីបអាស៊ី ភាគខាងត្បូង មានព្រំប្រទល់ភាគខាងជើងជាប់ប្រទេសចិន (ប្រវែង ១០៧៨ គ.ម) ហើយផ្នែកផ្សេងទៀត ជាប់ប្រទេសឥណ្ឌា ទាំងអស់តែម្តង (ប្រវែង ១៥៩៣ គ.ម)។ ប្រទេសនេប៉ាល់ មានផ្ទៃដីសរុបចំនួន ១៤៧ ១៨១ គីឡូម៉ែត្រក្រឡា។ ចំងាយពីព្រំប្រទល់ភាគ ខាងកើតទៅលិចមានប្រវែង ៨៨៥ គ.ម និងពីជើងទៅត្បូងចំងាយ១៩៣ គម។ ប្រទេសនេប៉ាល់ជាទីដែលភ្នំអ៊ីវើរេសត៍ដែលមានកំពស់ខ្ពស់ជាងគេបំផុតលើ ពិភពលោក (៨ ៨៤៨ ម៉ែត្រ)តាំងនៅ ហើយជាកន្លែងដែលព្រះពុទ្ធទ្រង់ប្រសូត្រនៅទីនោះផងដែរ។

ប្រទេសនេប៉ាល់បានរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកសភាធម្មនុញ្ញ ដើម្បីតាក់តែងរដ្ឋធម្មនុញ្ញថ្មីមួយ ក្រោយពីមានការឯកភាពគ្នារវាងភាគីជំលោះផ្ទៃក្នុងទាំងអស់។ ការបោះឆ្នោតបានប្រព្រឹត្តទៅនៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៨។

លទ្ធផលនៃការបោះឆ្នោតនេះបានធ្វើឱ្យបញ្ចប់របបរាជានិយម ដែលមានអាយុកាល ២៣៩ ឆ្នាំមកហើយនោះ ដោយសារសភាធម្មនុញ្ញបានបោះឆ្នោត ដោយសំលេងឆ្នោត ៥៦០ ទល់នឹង ៤ សំលេង នៃសមាជិកសភាធម្មនុញ្ញសរុប ចំនួន ៥៦៤ ដែលមានវត្តមានក្នុងចំណោមសមាជិកសភាធម្មនុញ្ញសរុបមានចំនួន៦០១រូប ដើម្បីទំលាក់របបរាជានិយម ហើយប្រកាសដាក់ប្រទេសនេប៉ាល់ជា**សាធារណរដ្ឋ** ដែលត្រូវរៀបចំដំណើរការក្រោមរដ្ឋធម្មនុញ្ញថ្មីមួយ។ ការបោះឆ្នោតបានប្រព្រឹត្តទៅនៅក្នុងសម័យប្រជុំលើកទី១ នាថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨។

## ប្រជាពលរដ្ឋ អ្នកបោះឆ្នោត

ក្នុងការបោះឆ្នោតថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៨ នេះ ប្រជាពលរដ្ឋនេប៉ាល់ចំនួន ជាង១១លាននាក់ (១១ ១៤៦ ៥៤០) ឬស្មើនឹង ៦៣,៣០% ចេញទៅបោះឆ្នោត ក្នុងចំណោមអ្នកមានសិទ្ធិបោះឆ្នោតចំនួនជាង១៧លាននាក់ (១៧ ៦០៩ ៨៩៥) ។ អ្នកបោះឆ្នោតនៅតំបន់ជនបទ ដាច់ស្រយាលគឺមានការយល់ដឹងទាប ហើយមានជីវភាពក្រីក្រខ្លាំង។ ប៉ុន្តែអ្វីដែលគួរឱ្យចាប់អារម្មណ៍គឺតាមរយៈការជួបសំភាសន៍ដោយផ្ទាល់ ឃើញថា អ្នកបោះឆ្នោតភាគច្រើនមាន សេចក្តីក្លាហាន ក្នុងការបោះឆ្នោតជ្រើសរើសគណបក្សនយោបាយ និងបេក្ខជនដែលខ្លួនពេញចិត្តនាពេលបច្ចុប្បន្នទោះ បីជាពួកគាត់ធ្លាប់បោះឆ្នោតគាំទ្រគណបក្ស ឬបេក្ខជនណាផ្សេងក្នុងការបោះឆ្នោតលើកមុនក៏ដោយ។ មានន័យថា អ្នកបោះឆ្នោតមិនប្រកាន់ជំហរដដែល១ ហើយបោះឆ្នោតគាំទ្រគណបក្សនយោបាយតែមួយនៅគ្រប់ការបោះឆ្នោតទាំងអស់ ទេ។ តាមការសិក្សាប្រៀបធៀបលទ្ធផលឆ្នោតតាមមណ្ឌលភាគច្រើននោះ បង្ហាញថា អ្នកបោះឆ្នោតនេប៉ាល់ ពិនិត្យមើលលក្ខណៈសម្បត្តិបេក្ខជនឯកត្តនាម និងលក្ខណៈសម្បត្តិគណបក្សនយោបាយ (ដែលត្រូវជ្រើសរើសតាមប្រព័ន្ធសមាមាត្រ) មុននឹងធ្វើការសំរេចចិត្តបោះឆ្នោត។ ជាក់ស្តែង នៅមណ្ឌលបោះឆ្នោតលេខ១ ក្នុងស្រុកកៃឡាលី (Kailali) ភាគខាងលិចបំផុតនៃប្រទេសនេប៉ាល់នោះគឺគណបក្សកុម្មុយនីសម៉ៅនិយមទទួលបាន សំលេងឆ្នោតចំនួនជាង២ម៉ឺន សន្លឹកក្នុងការបោះឆ្នោតឯកត្តនាម ប៉ុន្តែទទួលបានតែជាង៦ពាន់សន្លឹកប៉ុណ្ណោះក្នុងប្រព័ន្ធសមាមាត្រនោះ ដែលនេះ បង្ហាញថា អ្នកបោះឆ្នោតបានបោះឆ្នោតគាំទ្រគណបក្សមួយក្នុងប្រព័ន្ធឯកត្តនាម ហើយគាំទ្រ គណបក្សមួយផ្សេងទៀត ក្នុងការបោះឆ្នោតសមាមាត្រ ពោលគឺមិនបោះឆ្នោតឱ្យគណបក្សតែមួយដដែល១ទេ។

**គណបក្សនយោបាយ**

ប្រទេសនេប៉ាល់មានគណកបក្សនយោបាយទាំងអស់ចំនួន៧៤ ក្នុងនោះមានតែគណបក្សចំនួន៥៤ប៉ុណ្ណោះ ដែលបានចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត។ មានគណបក្សចំនួន៣ ដែលឈានមុខគេខាងកេរ្តិ៍ឈ្មោះ ក៏ដូចជា ធ្វើសកម្មភាពឃោសនាបោះឆ្នោតនោះ រួមមាន គណបក្សសភានេប៉ាល់ គណបក្សកុម្មុយនីសម៉ៅនិយម គណបក្ស កុម្មុយនីសម៉ាក្ស-លេនីននិយម ហើយក្រៅពីនេះមានគណបក្សតូចៗ ទើបបង្កើតថ្មីហើយបានដាក់បញ្ជី បេក្ខជនឈរឈ្មោះផងដែរ។ បណ្តាគណបក្សកុំម្មុយនីសតូចៗ ជាង១០ផ្សេងទៀតត្រូវបានបង្កើតឡើង ដែលបំបែកចេញពីគណបក្ស កុំម្មុយនីសធំពីរខាងលើ។ ជាទូទៅក្នុងស្នាក់ការកណ្តាល និងការិយាល័យគណបក្សកុំម្មុយ នីសមានការដាក់តាំងរូបថត តស្សរជនកុំម្មុយនីសល្បីល្បាញលើពិភពលោករួមមាន លោក ម៉ាក្ស ស៊ីស លោក លេនីន លោក អង់ គេល លោក ម៉ៅ សេទុងជាដើម។

**ប្រព័ន្ធបោះឆ្នោត**

ច្បាប់បោះឆ្នោតនេប៉ាល់កំណត់យកប្រព័ន្ធបោះឆ្នោតចំរុះដែលមានប្រព័ន្ធសមាមាត្រផង និងប្រព័ន្ធឯកត្តនាមផង។ អាសនៈចំនួន ២៤០ ត្រូវបានបោះឆ្នោតជ្រើសតាំងតាមប្រព័ន្ធឯកត្តនាម ហើយអាសនៈ៣៣៥ ត្រូវបោះឆ្នោតតាមប្រព័ន្ធឯកត្តនាម។

សំរាប់ប្រព័ន្ធឯកត្តនាម គឺគេចែក ក្នុងទូទាំងប្រទេសជា ២៤០មណ្ឌល (ក្នុង១មណ្ឌលមាន១អាសនៈ) ហើយ ក្នុងមណ្ឌលនីមួយៗជាការប្រមូលផ្តុំឃុំពី៣ទៅ៨ឃុំ ទៅតាមទំហំឃុំតូច ឬធំ និងប្រជាពលរដ្ឋតិច ឬច្រើន។ ក្នុងការគណនាលទ្ធផលឆ្នោតបេក្ខជនដែលទទួលបានសំលេងឆ្នោតច្រើនជាងគេគឺជាប់ឆ្នោតទទួលបានអាសនៈ១ប្រចាំមណ្ឌល តែម្តង (ទោះបីឈ្នះតែមួយសន្លឹកក៏ដោយ)។ ក្នុងការបោះឆ្នោតឯកត្តនាមនេះ មានទាំងបេក្ខជនមកពីគណបក្ស នយោបាយផង និងបេក្ខជនឯករាជ្យ (គ្មាននិន្នាការនយោបាយ និងមិនមែនជាសមាជិកគណបក្សនយោបាយ) ចូលរួមឈរឈ្មោះបានដូចគ្នា។ មានបេក្ខជនមកពីគណបក្សចំនួន៣១៣០រូប ហើយបេក្ខជនឯករាជ្យចំនួន៨១៦ បានចុះបញ្ជី បេក្ខជនឈរឈ្មោះ ក្នុងនោះបេក្ខជនមកពីគណបក្សនយោបាយចំនួន២៣៨បានជាប់ឆ្នោត រីឯបេក្ខជនឯករាជ្យដែល ជាប់ឆ្នោតមានតែ២រូបទេក្នុងចំណោមអាសនៈសរុបចំនួន២៤០នោះ។

រីឯប្រព័ន្ធសមាមាត្រគឺសំរាប់អាសនៈ៣៣៥ ដែលមានគណបក្សចំនួន៥៤ចូលរួម។ ច្បាប់បោះឆ្នោតនេប៉ាល់ កំណត់យកប្រទេសទាំងមូលធ្វើជាមណ្ឌលបោះឆ្នោតតែមួយ (ប្រហាក់ប្រហែលនឹងរបៀបដែលអនុវត្តនៅកម្ពុជាក្នុង ការបោះឆ្នោតឆ្នាំ១៩៩៣ ដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិផងដែរ) ហើយអាសនៈនឹងត្រូវបានបែងចែក ដល់គណបក្សនយោបាយសរុបទូទាំងប្រទេសតែម្តងដោយផ្អែកលើសមាមាត្រសន្លឹកឆ្នោតដែលគណបក្សទទួលបាន សរុបទូទាំងប្រទេសដែរ ហើយមិនមានការបែងចែកអាសនៈតាមមណ្ឌល ខេត្ត ឬស្រុកនោះទេ ដោយសារតំណាងនៅ ថ្នាក់ស្រុក និងឃុំគឺមានសមាជិកសភាធម្មនុញ្ញដែលជាប់ឆ្នោតតាមប្រព័ន្ធសមាមាត្រហើយ ។

*តទៅលេខក្រោយ*

**គណៈកម្មការព្រឹត្តិបត្រ**

១. លោក **គល់ បញ្ញា** ទីប្រឹក្សាផ្តល់យោបល់
២. លោក **ច័ន្ទ ដារិទ្ធ** ប្រធានសម្របសម្រួលព័ត៌មាន និងការផ្សាយ
៣. លោក **គាំង សុវណ្ណារេន** មន្ត្រីសម្របសម្រួលការនិពន្ធ និង ព្រឹត្តិបត្រ
៤. កញ្ញា **រស់ ស៊ីណាត់** សមាជិក

អាសយដ្ឋាន
ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់១
ខណ្ឌទួលគោក រាជធានីភ្នំពេញ កម្ពុជា
ប្រអប់សំបុត្រ ១១៤៥

ទូរស័ព្ទ ០២៣ ៨៨៤ ១៥០
ទូរសារ ០២៣ ៨៨៣ ៧៥០
អ៊ីម៉េល comfrel@online.com.kh
គេហទំព័រ www.comfrel.org

បើលោក អ្នកនាងកញ្ញាមានសំណួមពរ ចម្ងល់ ឬមានបំណងចូលរួមយោបល់ ឬស្នើសុំព្រឹត្តិបត្រសម្រាប់ស្ថាប័ន សូមទាក់ទងមកកាន់យើងខ្ញុំតាមរយៈអាសយដ្ឋានខាងលើនេះ។

ព្រឹត្តិបត្រ "អ្នកឃ្លាំមើល" ពីអង្គការសមាគម-មិនមែនរដ្ឋាភិបាល ទៅដល់ដៃប្រជាពលរដ្ឋនៅទូទាំងប្រទេស ដើម្បីភ្ជាប់ចន្លោះព័ត៌មានរវាងប្រជាពលរដ្ឋ និងអ្នកតំណាង និងអ្នកដឹកនាំពាក់ព័ន្ធក្នុងការចូលរួមស្ថាបនាសង្គមប្រជាធិបតេយ្យ ។

# សកម្មភាពការងាររបស់គណៈកម្មាធិការខុមហ្វ្រែល




វេទិកាគណបក្សនយោបាយស្តីពី អភិបាលកិច្ចដីធ្លី និងធនធានធម្មជាតិរៀបចំឡើង
ដោយ សមាគមអង្គការមិនមែនរដ្ឋាភិបាល




វេទិកាពិភាក្សានយោបាយស្តីពីវិធានការប្រឆាំងការជួញដូរស្ត្រី និងកុមារ
រៀបចំដោយខុមហ្វ្រែល



វេទិកាពិភាក្សានយោបាយស្តីពីវិធានការប្រឆាំងអំពើពុករលួយ




វេទិកាពិភាក្សានយោបាយស្តីពីបញ្ហាជាអាទិភាពចំនួនបីរបស់គណបក្សនយោបាយ